ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្ដីការគណៈរដ្ឋមន្ត្រី

ត្រីមាសទី២ ឆ្នាំ២០២១

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

ក ស វ




ECOSOCC

ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
www.ecosocc.gov.kh
info@ecosocc.kh
(855) 012 915 577 (855) 012 912 009

# គតិបណ្ឌិតរដ្ឋបុរសជាតិ

« គោលការណ៍នយោបាយឈ្នះ ឈ្នះ ៖

១. រក្សាសុវត្ថិភាព អាយុជីវិត

២. រក្សាកម្មសិទ្ធិ ទ្រព្យសម្បត្តិ

៣. រក្សាឋានៈ តួនាទី »

**សម្ដេចអគ្គមហាសេនាធិបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**
ថ្ងៃទី០៣ កុម្ភៈ ១៩៩៦

**ក្រុមការងារព្រឹត្តិបត្រ**

នាយកគ្រប់គ្រង

- យឹម ណុលសន

និពន្ធនាយក

- អ៊ីវ ចុង

ការិយាល័យនិពន្ធ

- នរ៉ាណាឫទ្ធិ អានន្ទជាយ៉ាត
- លី គឹមសុខ
- ឆយ អូន
- ទីប្រឹក្សាបច្ចេកទេស
- សមាជិក-សមាជិកា នៃក្រុមប្រឹក្សាសេដ្ឋ-កិច្ច សង្គមកិច្ច និង វប្បធម៌

អ្នកចាត់ចែងផលិត

- ប៉ិច សុខា
- អ៊ិន គុលា

អ្នកចែកផ្សាយ

- អៀង វដ្ឋា
- សេក វុទ្ធី

ការីកុំព្យូទ័រ

- អេង រត្នមុនី
- សយ វាស្នា
- យឹម ច័ន្ទតារា

# មាតិកា

ទំព័រ


I- បទអត្ថាធិប្បាយ គុណធម៌ ១-៤

II- ការពិនិត្យផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

១- សេចក្តីព្រាងអនុក្រឹត្យស្តីពីការបន្ថែមរបបសន្តិសុខសង្គមសម្រាប់អតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន និងសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ៥-៧

២- សក្តានុពលសេដ្ឋកិច្ចនិងបរិយាកាសវិនិយោគរបស់កម្ពុជានឹងត្រូវបានពង្រីកតាមរយៈកិច្ចព្រមព្រៀងស្តីពីការវិនិយោគក្រោមកិច្ចព្រមព្រៀងគោលស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយ រវាងប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋឥណ្ឌា ៨-៩

III- បទវិភាគ៖

១- ឥណ្ឌានឹងបាត់បង់ផលប្រយោជន៍ច្រើនពី Quad ១០

២- សម្តេចតេជោ ហ៊ុន សែន ប្រកាន់នយោបាយចម្រុះពណ៌ ១១-១២

IV- ការសិក្សា

១- ការវិវត្តនៃប្រព័ន្ធទឹកសាប និងប្រវត្តិនៃវិស័យជលផលទឹកសាបកម្ពុជា (តចប់) ១៣-១៧

២- ការប្រើប្រាស់ថាមពលអគ្គិសនីពីពន្លឺព្រះអាទិត្យ ១៨-២១

V- នាទីវប្បធម៌

១- បច្ចេកសព្ទភូមិវិទ្យានិងប្រវត្តិវិទ្យា ២២-២៣

២- ស្វែងយល់អំពីប្រពៃណីកាន់បិណ្ឌនិងភ្ជុំបិណ្ឌ ២៤-២៩

VI- នាទីកំណាព្យ

- មោហោ (កាកគតិ) ៣០

VII- នាទីកំសាន្ត

១- ល្បើកដើមទៀប និង ដើមសេដា ៣១

២- ល្បើកទន្សាយ និង ពពែ ៣១

# គុណធម៌

គុណធម៌ គឺជាសេចក្ដីល្អដែលមានដំណើរចម្រើននូវសេចក្ដីសុខ។

**ក. តាមគំហើញទូទៅរបស់សង្គមមនុស្ស :**

គុណធម៌ដែលបុគ្គលគួរប្រកាន់យកមាន៧យ៉ាង ៖

១. ចិញ្ចឹមម្ដាយឪពុករហូតអស់ជីវិត

២. គោរពរៀមច្បងក្នុងត្រកូល

៣. ប្រើសំដីផ្អែមល្ហែម

៤. មិននិយាយស៊កសៀតបៀតបៀន

៥. មិនកំណាញ់ស្វិត

៦. មិនខឹងឆេវឆាវ

៧. និយាយការពិត

**ខ. តាមទស្សនវិជ្ជា :**

ដែលហៅថា«គុណធម៌»គឺជាជីវិតផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗចំពោះសង្គមដែលខ្លួនរស់នៅ។គុណធម៌នេះមានតម្លៃសម្រាប់តែមនុស្សទាំងឡាយណាដែលមានសញ្ចេតនាប្រកបដោយកុសល។សង្គមមនុស្សបានជួយឱ្យតម្លៃទៅមនុស្សព្រមទាំងជួយធ្វើឱ្យបានសម្រេច«ឧត្ដមគតិ»ខ្លះរបស់មនុស្ស។ក្រមសីលធម៌ដែលយើងសន្មត់ថាជាផ្នែកមួយនៃគុណធម៌របស់មនុស្សនោះបានញ៉ាំងមនុស្សឲ្យទទួលស្គាល់កុសលដោយភាគច្រើន។ មិនតែប៉ុននោះសោតក្រមសីលធម៌ធ្វើមនុស្សក្នុងសង្គមឱ្យមានលក្ខណៈជាមនុស្សមែនទែន។គឺទំនួលខុសត្រូវ ដែលក្រមសីលធម៌ និងឧត្ដមគតិបានខំពូតសន្សំទុកឱ្យមនុស្សសម្រេចបំណងធំៗរបស់ខ្លួន ព្រមទាំងហ៊ានអារកាត់ចំពោះបញ្ហាផ្សេងៗ។ ឧទាហរណ៍ :

១. មនុស្សសម័យបច្ចុប្បន្នបានសម្រេចរើសគូស្រករដោយខ្លួនឯង។

២.មនុស្សអាចរើសមុខងាររបស់ខ្លួនក្នុងសង្គមដោយពុំគោរពទំនៀមទម្លាប់និងប្រពៃណីខ្លះដែលតម្រូវឱ្យមនុស្សទទួលអនុវត្តទាំងទើសទាល់។ ដូចជាពួកបាគូគឺព្រាហ្មណ៍ ដែលមានតួនាទីរក្សាព្រះខ័នរាជ្យស្ដេច ទទួលភារៈប្រារព្ធពិធីផ្សេងៗ ក្នុងរាជានិយមព្រហ្មញ្ញសាសនា ត្រូវមានកូន ឬក្មួយប្រុស ឬប្អូនប្រុសរបស់ខ្លួនដើម្បីបន្តតំណែងតទៅទៀត។ តែគេឃើញថាជិតមួយសតវត្សមកហើយនៅប្រទេសខ្មែរ កូនប្រុសបាគូបានជ្រើសរើសការងារដោយខ្លួនឯង ហើយហ៊ានប្រឆាំងនឹងប្រពៃណីរបស់ខ្លួនដោយកាត់ផ្នួងសក់អស់គ្មានសល់។ កូនចៅបាគូបានចៀសវាងករណីយកិច្ចតាមប្រពៃណីរបស់ខ្លួនដោយឥតញញើតញញើម។នេះជាកត្តាបញ្ជាក់ឱ្យយើងឃើញថាមនុស្សបានពង្រីកបុគ្គលិកទៅជាលក្ខណៈសកលដូចជាហ៊ានទទួលខុសត្រូវលើការរើសតំណាងរបស់ខ្លួននៅក្នុងសង្គមដើម្បីត្រួតត្រា...។

គុណធម៌ពិត : គឺសីលតម្លៃរបស់បុគ្គល ដែលមានមនោសញ្ចេតនារស់។

១.សញ្ញាណនៃគុណធម៌:គឺការប្រាប់ភាពពិតនៃគុណធម៌,គឺការចង្អុលប្រាប់ពីលក្ខណៈពិតនៃគុណធម៌ ឬក៏ជា«លក្ខណៈសច្ចៈរបស់គុណធម៌» ក៏បាន។

២. កម្លាំងគុណធម៌ : គឺកម្លាំងនៃចិត្តមនុស្សដែលញ៉ាំងឱ្យសាងកុសល។ លោក ឡឺសែន (Le Seine) យល់ថា «គុណធម៌» គឺសេចក្តីក្លាហានក្នុងការស្វែងរកកុសល។ ឯចំណែកលោក រ៉ឺនូវីយេ (Renouvier) យល់ថា « គុណធម៌ » គឺជាកម្លាំងដែលមានការពិចារណា ការជជែកផ្ទួង សេរីភាព ភាពជាម្ចាស់លើខ្លួនឯង ដំណឹកនាំ ឬចំណាត់ចំណែងដោយខ្លួនឯង (direction de soi)។ លោក ដេកាត (Descartes) យល់ថា គុណធម៌គឺ «ចិត្តបុណ្យ» (générosité)។ ដទៃពីនេះ គុណធម៌គឺ « សេចក្តីខ្ជាប់ខ្ជួន » (constance) « សេចក្តីព្យាយាម» (persévérance) ឬជា «ទម្លាប់នៃកុសល»។ ខ្លះទៀតបានឱ្យនិយមន័យថា«គុណធម៌គឺជាឆន្ទៈច្បាស់លាស់នៅក្នុងសីលចរិយា,ជាលំនៅអចិន្ត្រៃយ៍ដែលកើតមកពីការប្រឹងប្រែង»។

៣. លក្ខណៈគុណធម៌ : គុណធម៌របស់មនុស្សមានច្រើនបែប ច្រើនយ៉ាងណាស់ ហើយមានលក្ខណៈពុំដូចគ្នាទាំងអស់ទេ។ ហេតុដូចនេះហើយ បានជាគេអាចចែកគុណធម៌ជាពីរពួកផ្សេងៗគ្នា ៖

៣១. គុណធម៌សាមញ្ញ គឺជាគុណធម៌ដែលបានមកពីការហ្វឹកហ្វឺន និងការអប់រំ។ ឧទាហរណ៍ ៖

- ការទៀងពេល (ponctualité)
- ការចេះប្រមាណមិនឲ្យហួស (sobriété)
- ភក្តីភាព (loyauté)
- ភាពខ្ជាប់ខ្ជួន (constance)
- ការគួរសម (politesse)

៣២. គុណធម៌កំណើត គឺជាគុណធម៌ដែលមនុស្សបានទទួលមរតក ពីក្នុងពោះមាតារបស់ខ្លួនមក។ ឧទាហរណ៍ :

- ចិត្តល្អ (bonté)
- ភាពមិនរឹងរូស (docilité)
- ចិត្តសន្តោស - មេត្តា - ករុណា ...

៤. គុណធម៌របស់អារីស្តូត : លោក អារីស្តូត (Aristote) បានចែក « គុណធម៌ » ជាពីរពួកធំៗគឺ ៖

៤១. បញ្ញាគុណធម៌ គឺជាគុណធម៌ដែលធ្វើឲ្យបញ្ញារិះគិតកាន់តែល្អឡើង ដើម្បីសាងពុទ្ធិខាងសច្ចៈ។ ឧទាហរណ៍ ៖

- សិល្បៈ (Art)
- ស្យង់ (Science)
- ការប្រុងប្រយ័ត្ន (prudence)
- គតិបណ្ឌិត (Sagesse)
- បញ្ញា (Intelligence)...

៤២. សីលគុណធម៌ គឺជាគុណធម៌ដែលមាននៅក្នុងទម្លាប់ ដែលចេះគ្របសង្កត់លើសម្ទុះជំរុញវិចារណញាណ និងក្នុងទម្លាប់ប្រព្រឹត្តឲ្យសមរម្យត្រឹមត្រូវ ទោះជានៅក្នុងស្ថានភាពណាក៏ដោយ។ ឧទាហរណ៍ ៖

- សេចក្ដីក្លាហាន (Courage)
- ការចេះប្រមាណ (Tempérance)
- យុត្តិធម៌ (Justice)
- គតិបណ្ឌិត (Sagesse)...

៥. នៅក្នុងជំនឿសាសនាគ្រីស្ត ព្រះសង្ឃព្រះនាម សាំង តូម៉ា (Saint Thomas) ក្រៅអំពីបានគាំទ្រទស្សនៈលោកអារីស្តូតមក លោកបានបន្ថែមគុណធម៌ផ្សេងៗ ដូចតទៅនេះ ៖

១. ជំនឿចំពោះព្រះគ្រីស្ត ( Foi)
២. ការសង្ឃឹម (Espérance)
៣. សប្បុរសធម៌ (Charité)

គុណធម៌ទាំងបីនេះ លោកសាំងតូម៉ាបានឲ្យឈ្មោះថា« ទេវកម្មវត្ថុគុណធម៌ »។

៦.នៅក្នុងជំនឿសាសនាអ៊ីស្លាមគុណធម៌គឺជាការសម្រេចចិត្តក្នុងការធ្វើ«អត្តពលី»(sacrifice) ពោលគឺការបូជាជីវិតខ្លួនថ្វាយព្រះអាឡាហ៍។

៧. នៅក្នុងជំនឿព្រហ្មញ្ញសាសនា ក្រៅពីគុណធម៌សាមញ្ញ គេបានសង្កេតឃើញមាន ការហ៊ានធ្វើពិធីបូជាយញ្ញ និងធ្វើតបៈធម៌ ហើយនិងការ តម្រង់ស្មារតីទៅលើព្រះអាទិទេពអង្គណាមួយ។

៨. នៅក្នុងជំនឿព្រះពុទ្ធសាសនា គេបានឃើញ « គុណធម៌ » ពោលគឺបារមី១០ ដែលព្រះពុទ្ធអង្គបានខំសាងគ្រប់ជាតិ។ ឧទាហរណ៍ : ទសបារមី ៖

| | | |
|---|---|---|
| ១.ទានបារមី | = | ធ្វើអំណោយ (ក្នុងមហាវេស្សន្តរជាតក) |
| ២.សីលបារមី | = | រក្សាកាយវាចារឲ្យល្អបរិសុទ្ធប្រពៃ (ក្នុងភូរិទត្តជាតក) |
| ៣.នេក្ខម្មបារមី | = | ចេញបួសលះបង់កាមគុណ (ក្នុងតេមិយជាតក) |
| ៤.បញ្ញាបារមី | = | ដឹងច្បាស់នូវគំនិតដើម្បីចោទស្រាយបញ្ហាដោយល្បិច (ក្នុងមហោសថជាតក) |
| ៥.វិរិយបារមី | = | សង្វាតធ្វើការមិនទម្លាក់ចោលកណ្ដាលផ្លូវ(ក្នុងមហាជនកជាតក) |
| ៦.ខន្តីបារមី | = | អត់ធន់នឹងសេចក្ដីទុក្ខ (ក្នុងចន្ទកុមារជាតក) |
| ៧.សច្ចបារមី | = | កាន់ពាក្យពិតមិនរុះរើ (ក្នុងវិធុរជាតក) |
| ៨.អធិដ្ឋានបារមី | = | តាំង(ប៉ង)ចិត្តមាំដើម្បីឲ្យបានសម្រេច (ក្នុងនេមិរាជជាតក) |
| ៩.មេត្តាបារមី | = | ផ្សព្វផ្សាយសេចក្ដីរាប់អានចំពោះសត្វមិនរើសមុខ (ក្នុងសុវណ្ណសាមជាតក) |
| ១០.ឧបេក្ខាបារមី | = | តាំងចិត្តជាកណ្ដាលមិនលំអៀងទៅខាងណា(ក្នុងនារទជាតក) |

ក្រៅពីទ្រឹស្ដី « គុណធម៌ » នៅមានអំពើល្អរបស់មនុស្សជាច្រើនទៀត ដែលអ្នកប្រាជ្ញយល់ថាមានតម្លៃគុណធម៌ ដូចជា ៖

- សុក្រឹតភាព ឬភាពល្អឥតខ្ចោះ (perfection)
- គុណូបការៈ ឬសីលតំលៃ (mérite)...

**គ. មនុស្សថ្លៃ** ( Personnes de valeurs ) :

គឺជាមនុស្សទាំងឡាយណា ដែលមានគុណធម៌ឬគុណូបការៈសំខាន់ ឬខ្ពស់ជាងគេ។ ឧទាហរណ៍ : រង្វាន់ណូបែលផ្នែកអក្សរសាស្រ្ត បានឲ្យជារង្វាន់ចំពោះតែ « មនុស្សថ្លៃ » ដូចជាលោក កាមុស ( Camus ) សាត្រ ( Satre ) ស៊ុលស៊ីនីត ស៊ិន ប៊ែណាដាំង ដឺ សាំងព្យែរ...

ចំពោះមនុស្សថ្លៃ គេបានចែកជាបីផ្នែកធំៗ ដើម្បីងាយស្រួលចំណាំ :

គ១. បណ្ឌិត( Sage ) គឺជាមនុស្សដែលមានចំណង់ទាញ ( inspiration ) ប្រកបដោយបញ្ញានិយម ( intellectualisme )។ មានរបៀបជីវិត ( style de vie ) ប្រកបដោយលំនឹង ( équilibre ) មានឥរិយាបថធម្មជាតិស្របនឹងវិវត្តន៍ធម្មជាតិ។ មានឥរិយាបថឥន្ទ្រីយភាព ( attitude envers la sensibilité ) មិនរំភើប ញាប់ញ័រហួសហេតុ។មានឥរិយាបថចំពោះអ្នកដទៃ ប្រកបដោយលក្ខណៈជាបុគ្គលនិយម( individualisme )។ មិនគិតប្រយោជន៍ផ្ទាល់ខ្លួន ហើយប្រកាន់ជំនឿថា គុណធម៌ជារង្វាន់ផ្ទាល់ខ្លួនរបស់បណ្ឌិត។

គ២. វីរបុរស ( Héro ) គឺជាមនុស្សដែលមានចំណង់ទាញ ប្រកបដោយសន្ទុះសភាវគតិ ( élan instinctif )។ មានរបៀបរស់នៅប្រកបដោយភាពក្លៀវក្លាហួសជនដទៃ។ មានឥរិយាបថធម្មជាតិ ជាអ្នកឈ្នះលើធម្មជាតិ។ មានឥរិយាបថឥន្ទ្រីយភាពប្រកបដោយលំងប់ ( passion )។ មានឥរិយាបថចំពោះអ្នកដទៃ ជាបុគ្គលនិយមហួសហេតុ ( ultra – individualisme ) ហើយជាមនុស្សប្រកបដោយចិត្តបុណ្យ ( générosité )។

គ៣. សន្តបុគ្គល ( Saint ) គឺជាមនុស្សដែលមានចំណង់ទាញ ប្រកបដោយជំនឿទៅលើសាសនា។ មានរបៀបរស់នៅជាជនដែលស្វែងរក ឥតឈប់ឈរនូវសុក្រឹតភាព។ មានឥរិយាបថធម្មជាតិជាអតិសេដ្ឋ ( trans cendance ) ហើយយល់កិច្ចការទាំងអស់ដែលនៅក្រៅធម្មជាតិ។ មានឥរិយា បថឥន្ទ្រីយភាពខុសពីជនដទៃ ពោលគឺធ្វើតបៈ ( ascétisme ) រកបរមសុខក្រៅលោក។ ចំពោះអ្នកដទៃ គេជាមនុស្សប្រកបដោយកម្រិតអធ្យាស្រ័យ និងជាបុគ្គលដែលមានបារម្ភជានិច្ចទៅលើសុគតិភព។ សន្តបុគ្គលច្រើនជាមនុស្សស្អប់លោកិយ ធុញនឹងលោកិយ ហើយជឿថាមានតែបរលោកទេ ដែលមានយុត្តិធម៌ពិត និងមានសុភមង្គលពិត។

## ១- សេចក្តីព្រាងអនុក្រឹត្យស្តីពីការបន្ថែមរបបសន្តិសុខសង្គម សម្រាប់អតីតមន្ត្រីរាជការស៊ីវិលនិងអតីតយុទ្ធជន និង សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

យោងតាមលិខិតស្នើសុំរបស់ក្រសួងមុខងារសាធារណៈ លេខ១០៧០ មស.លអជ ចុះថ្ងៃទី៧ ខែមេសា ឆ្នាំ២០២១ និងតាមចំណារដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រី ប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ឯកឧត្តមទេសរដ្ឋមន្ត្រី **យឹម ណុលឡា** ប្រធាន ក.ស.វ. បានឯកភាពតាមសំណើរបស់ឯកឧត្តម **លី គឹមសុខ** អនុប្រធានក.ស.វ. និងជាប្រធានក្រុមការងារទី១ ក.ស.វ ចាត់តាំងឯកឧត្តម **សួន លាងហៃ** អនុប្រធានក្រុមការងារ ចូលរួមពិនិត្យនិងពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យ ចំនួនពីរដែលរៀបចំឡើងដោយក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទានិងដាក់ជូនពិនិត្យ ពិភាក្សា ផ្តល់យោបល់ក្រសួងមុខងារសាធារណៈ តាមរយៈការប្រជុំមួយកាលពីថ្ងៃទី២ ខែមេសា ឆ្នាំ២០២១ តាមប្រព័ន្ធ អនឡាញ ដឹកនាំដោយ ឯកឧត្តម **យក់ ប៊ុនណា** រដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ។

សេចក្តីព្រាងអនុក្រឹត្យទាំងពីរនោះរួមមាន៖ ១.សេចក្តីព្រាងអនុក្រឹត្យស្តីពីការបន្ថែមរបបសន្តិសុខសង្គម សម្រាប់អតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន និង ២.សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្ត ទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

**១.សេចក្តីព្រាងអនុក្រឹត្យស្តីពីការបន្ថែមរបបសន្តិសុខសង្គមសម្រាប់អតីតមន្ត្រីរាជការស៊ីវិល និងអតីត យុទ្ធជន**

ចំពោះសេចក្តីព្រាងអនុក្រឹត្យនេះក្រសួងមុខងារសាធារណៈបានឯកភាពលើការស្នើសុំកែសម្រួលបន្ថែម របបសន្តិសុខសង្គមប្រចាំខែ ដែលទាបជាង ៦៨០ ០០០ រៀល ឱ្យដល់ត្រឹម ៦៨០ ០០០រៀល ដែលត្រូវអនុវត្ត ក្នុងឆ្នាំ២០១១។

សេចក្តីព្រាងអនុក្រឹត្យស្តីពីការបន្ថែមរបបសន្តិសុខសង្គមមានបីមាត្រា។មាត្រា១ចែងពីការដំឡើងរបប សន្តិសុខប្រចាំខែដែលទាបជាង ៦៨ម៉ឺនរៀល ឱ្យដល់ ៦៨ម៉ឺនរៀល។ មាត្រា២ ចែងពីកាលបរិច្ឆេទអនុវត្តដែល គ្រោងចាប់ពីថ្ងៃទី១ ខែឧសភា ឆ្នាំ២០២១។ មាត្រា៣ គឺមាត្រាបញ្ចប់។

សេចក្តីព្រាងនេះរៀបចំឡើងទៅតាមការចង្អុលបង្ហាញរបស់ព្រះរាជក្រឹត្យស្តីពីរបបសន្តិសុខសង្គម សម្រាប់មន្ត្រីរាជការស៊ីវិល (មាត្រា៧) និងព្រះរាជក្រឹត្យស្តីពីរបបសន្តិសុខសង្គមសម្រាប់អតីតយុទ្ធជន (មាត្រា៦) ដែលបញ្ញត្តថា "ការកែប្រែការតាលិកនៃរបបសន្តិសុខសង្គម និងការផ្តល់បន្ថែមនូវការតាលិកដទៃទៀតត្រូវ កំណត់ដោយអនុក្រឹត្យ"។

ចំណងជើង និងរបៀបតាក់តែងសេចក្តីគឺដូចគ្នាទៅនឹងអនុក្រឹត្យប្រភេទដូចគ្នាមុនៗចំនួនពីរដែលកំពុង ស្ថិតនៅជាធរមាន នោះគឺអនុក្រឹត្យលេខ៤១អនក្រ.បក ចុះថ្ងៃទី១ ខែមេសា ឆ្នាំ២០១៥ និងអនុក្រឹត្យលេខ៣៦

អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដែលស្ដីពីបន្ថែមរបបសន្តិសុខសម្រាប់មន្ត្រីរាជការ និងអតីតយុទ្ធ-ជនដូចគ្នា។

តំណាងក.ស.វ.បានចូលរួមយោបល់ដោយស្នើសុំឱ្យមានការកែសម្រួលពាក្យពេចន៍ក្នុងមាត្រា១ឱ្យដូចចំណងជើង គឺពាក្យ "ត្រូវដំឡើងឱ្យដល់" ទៅជា "ត្រូវបន្ថែមឱ្យដល់"។ ចំពោះមាត្រា២ កថាខ័ណ្ឌទី២ ខ្លឹមសារនេះមានចែងរួចហើយក្នុងព្រះរាជក្រឹត្យស្ដីពីរបបសន្តិសុខដូចបានលើកឡើងខាងលើ។ដូច្នេះអាចមិនចែងទៀតក៏បាន។

**២.សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

សេចក្ដីព្រាងអនុក្រឹត្យស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវ-នីតិសម្បទាត្រូវបានរៀបចំឡើងវិញ ដាក់សុំយោបល់កែសម្រួលពីសមាជិកក្រុមតេឡេក្រាមបន្ទាប់ពីក្រសួងមុខងារសាធារណៈបានឯកភាពលើសេចក្ដីស្នើសុំបន្ថែមអគ្គនាយកដ្ឋានចំនួន២សរុបទាំងចាស់ទាំងថ្មីត្រូវជា៤ និងឯកភាពផ្ដល់នាយកដ្ឋានត្រឹមចំនួន១៧ លើសេចក្ដីស្នើសុំចំនួន២០។

ជារួមសេចក្ដីព្រាងអនុក្រឹត្យថ្មីនេះ មានការរៀបចំបានល្អស្របទៅតាមច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី និងការវិវត្តនៃការងារសង្គមកិច្ចរបស់ប្រទេសជាតិ។ ការតាក់តែងសេចក្ដីក៏អនុវត្តបានល្អស្របទៅតាមគោលការណ៍ណែនាំស្ដីពីនីតិវិធីនិងវិធាននៃការតាក់តែងសេចក្ដីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ដែលបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៣ និងទៅតាមគំរូនៃអនុក្រឹត្យប្រភេទដូចគ្នា ដែលបានដាក់ចេញជាបន្តបន្ទាប់ បន្ទាប់ពីច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី មានជាអាទិ៍ អនុក្រឹត្យស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃទីស្ដីការគណៈរដ្ឋមន្ត្រី។

សេចក្ដីព្រាងអនុក្រឹត្យស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវ-នីតិសម្បទា មាន១៧ជំពូក និង៨៧មាត្រា មានជំពូកបទប្បញ្ញត្តិទូទៅ ជំពូកបេសកកម្ម មុខងារ ភារកិច្ច និងរចនាសម្ព័ន្ធនិងជំពូកបន្តបន្ទាប់ស្ដីពីរចនាសម្ព័ន្ធនិងពីអង្គភាពផ្សេងៗចំណុះក្រសួងរាប់ចាប់តាំងពីខុទ្ទកាល័យរដ្ឋមន្ត្រី អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាលនិងហិរញ្ញវត្ថុរហូតដល់អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ។ ជំពូកចុងក្រោយចំនួន៣ រួមមាន មួយស្ដីពីបទប្បបញ្ញត្តិដោយឡែក មួយស្ដីពីអន្តរប្បញ្ញត្តិ និងមួយទៀតស្ដីពីអវសានប្បញ្ញត្តិ។

សេចក្ដីព្រាងអនុក្រឹត្យនេះគ្រោងនឹងដាក់សុំហត្ថលេខាសម្ដេចនាយករដ្ឋមន្ត្រីតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដូចមានយោងនៅក្នុងគំនូសចុងក្រោយនៃមូលបទ។

ដោយសារបញ្ហាកែសម្រួលរចនាសម្ព័ន្ធក្រសួងមុខងារសាធារណៈបានពិនិត្យពិភាក្សា និងដោះស្រាយរួចហើយ តាមរយៈអង្គប្រជុំថ្ងៃទី២ ខែមេសា ឆ្នាំ២០២១ ហើយបញ្ហាជាន់ភារកិច្ចដែលអាចមានជាមួយក្រសួងស្ថាប័នផ្សេងទៀតមិនអាចពិនិត្យពិចារណាបានតាមក្រុមតេឡេក្រាម តំណាង ក.ស.វ. បានធ្វើការចូលរួមផ្ដល់យោបល់តែលើសេចក្ដីព្រាងដែលមាននៅលើក្រដាសប៉ុណ្ណោះ មិនមានការឆ្លើយឆ្លងបញ្ចេញមតិយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធឡើយ។

សំណើកែសម្រួលមានជាអាទិ៍ការលុបចោលពាក្យ "មានគោលបំណង" ក្នុងមាត្រា១។ មាត្រា២ ក៏មានការពិនិត្យពិចារណា លើកហេតុផលឱ្យមានការរៀបចំជាថ្មីចែងតែពីមុខងារនិងភារកិច្ចចម្បងៗរបស់ក្រសួង កុំរៀបរាប់ច្រើនពេក ទុកលម្អិតទៅក្នុងជំពូកស្តីពីអគ្គនាយកដ្ឋានចំណុះក្រសួងវិញ។ ពាក្យពេចន៍ដែលប្រើក្នុងមាត្រា៤ គប្បីប្រើឱ្យដូចគ្នានៅក្នុងជំពូកបន្តបន្ទាប់នៃសេចក្តីព្រាង នោះគឺចំណុចខដែលពាក់ព័ន្ធនឹងជំពូកទី១៣។ ការប្រើពាក្យ"និង" និងពាក្យ"ឬ" ក៏ត្រូវបានស្នើឱ្យប្រើដោយប្រុងប្រយ័ត្ន។

ពាក្យ"និង"គឺសម្រាប់បូកបន្ថែមរីឯពាក្យ"ឬ"គឺបង្ហាញអំពីជម្រើស។ដូច្នេះចំពោះមាត្រា៤ការប្រើពាក្យ "និង" គឺត្រូវជាង។ នៅក្នុងមាត្រាដដែលនេះ គប្បីមានសញ្ញា"។" នៅចុងបញ្ចប់ចំណុច "ក"។

ល្បះស្តីពីអង្គការលេខរបស់ក្រសួង ដែលដាក់នៅចុងមាត្រា៥ បើគិតពីឡូស៊ីកក្នុងការតែងសេចក្តី គួរដាក់នៅចុងមាត្រា៤ដែលនិយាយពីរចនាសម្ព័ន្ធនោះវិញ។

នៅក្នុងមាត្រាដំបូងនៃជំពូកស្តីពីអគ្គនាយកដ្ឋាន កថាខ័ណ្ឌចុងក្រោយចែងថា "... និងអនុវត្តភារកិច្ចផ្សេងៗទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន" រីឯគំនូសចុងក្រោយស្តីពីភារកិច្ចរបស់នាយកដ្ឋាន ក៏ចែងប្រហែលគ្នានេះដែរ គឺ " អនុវត្តភារកិច្ចផ្សេងៗទៀតដែលអគ្គនាយកនិងថ្នាក់ដឹកនាំប្រគល់ជូន"។

ដូច្នេះ បើយើងប្រើពាក្យ "ថ្នាក់ដឹកនាំ" ដែលសំដៅដល់រដ្ឋមន្ត្រីផង ដល់អគ្គនាយកនិងថ្នាក់ដឹកនាំផ្សេងទៀតផងនោះយើងអាចលុបគំនូសភារកិច្ចចុងក្រោយរបស់នាយកដ្ឋាននីមួយៗចេញដោយរក្សាទុកកថាខ័ណ្ឌទី២ នៃមាត្រាដំបូងនៃជំពូកស្តីពីអគ្គនាយកដ្ឋាន និងប្តូរពាក្យ"រដ្ឋមន្ត្រី" ទៅជា "ថ្នាក់ដឹកនាំ" ជាការស្រេចមិនមានការសរសេរដដែលៗនៅចុងមាត្រាស្តីពីនាយកដ្ឋានទៀតឡើយ។

ចំពោះការរៀបចំជំពូក ដើម្បីឱ្យមានលំដាប់លំដោយល្អ មានសង្គតិភាព គួរយកតាមលំដាប់លំដោយដែលមានចែងនៅក្នុងមាត្រា៤គឺបន្ទាប់ពីជំពូកនាយកដ្ឋានសវនកម្មផ្ទៃក្នុងគួរចែងពីជំពូកគ្រឹះស្ថានសាធារណៈរដ្ឋបាល ហើយជាបន្ទាប់ គឺជំពូកមណ្ឌល មជ្ឈមណ្ឌលជាតិ... និងជំពូកអង្គភាពថ្នាក់ក្រោមជាតិ។ ដូច្នេះជំពូកទី១៣ គួរដូរទៅជាជំពូកទី១១ ជំពូកមណ្ឌល មជ្ឈមណ្ឌលជាតិ... ដូរទៅជាជំពូកទី១២ ហើយជំពូកអង្គភាពថ្នាក់ក្រោមជាតិ ដាក់នៅខាងក្រោយជាជំពូកទី១៣វិញ។

ក្រៅពីការលើកមតិយោបល់កែលម្អ តំណាង ក.ស.រ. បានធ្វើទំនាក់ទំនងជាប់ជាប្រចាំ ជាមួយក្រុមការងាររៀបចំសេចក្តីព្រាងអនុក្រឹត្យរបស់ក្រសួង ដើម្បីជួយពិនិត្យសេចក្តីព្រាងដែលរៀបចំឡើងបន្ទាប់ពីទទួលបានយោបល់ចូលរួមពីសមាជិករបស់ក្រុមតេឡេក្រាម ឈានទៅតាក់តែងសេចក្តីព្រាងចុងក្រោយ ដាក់ជូនថ្នាក់ដឹកនាំក្រសួងពិនិត្យនិងសម្រេចឱ្យបានមុនដំណាច់ខែមេសា ឆ្នាំ២០២១។

*ក.ស.រ. - ក្រុម ១*

## ២- សក្តានុពលសេដ្ឋកិច្ច និងបរិយាកាសវិនិយោគរបស់កម្ពុជា នឹងត្រូវបានពង្រីកតាមរយៈកិច្ចព្រមព្រៀងស្តីពីការវិនិយោគ ក្រោមកិច្ចព្រមព្រៀងគោលស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ទូលំទូលាយរវាងប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋឥណ្ឌា

### ខ្លឹមសារសង្ខេប

កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋឥណ្ឌា មានគោលបំណងសំខាន់ក្នុងការជម្រុញការវិនិយោគនិងបង្កើនការវិនិយោគដោយសេរីងាយស្រួលប្រកបទៅដោយតម្លាភាពនិងធានានៃការវិនិយោគស្មើភាពនៃបណ្តាប្រទេសជាសមាជិកក្នុងការផ្តល់ផលប្រយោជន៍និងការការពារចំពោះ វិនិយោគទៅវិញទៅមក។ ជាមួយគ្នានេះដែរ កិច្ចព្រមព្រៀងនេះ បានឆ្លុះបញ្ចាំងអំពីការប្តេជ្ញារបស់ប្រទេសទាំងអស់ ដើម្បីបង្កើតនិងលើកកម្ពស់តំបន់ពាណិជ្ជកម្ម និងវិនិយោគក្នុងតំបន់អាស៊ានឥណ្ឌាមួយ ដែលរួមមានតំបន់ពាណិជ្ជកម្មសេរីសម្រាប់ទំនិញ សេវាកម្ម និងការវិនិយោគ។

ខ្លឹមសាររួមនៃកិច្ចព្រមព្រៀងនេះបានបញ្ជាក់នូវចំនុចសំខាន់ៗជាច្រើនដែលទាក់ទងនឹងការធានារបស់ភាគីម្ខាងចំពោះការវិនិយោគនៅលើទឹកដីរបស់ខ្លួនដោយស្មើភាពគ្មានការរើសអើងប្រកបដោយសមធម៌និងការការពារនូវសន្តិសុខពេញលេញជូនវិនិយោគិននៃភាគីម្ខាងទៀតឬវិនិយោគិននៃរដ្ឋដែលមិនមែនជាភាគីពាក់ព័ន្ធ និងការគ្រប់គ្រងកិច្ចដំណើរការប្រតិបត្តិការ ការប្រើប្រាស់ ការលក់ ឬការចាត់ចែងផ្សេងៗទៀតនៃការវិនិយោគក្នុងទឹកដីរបស់ខ្លួន ព្រមទាំងផ្តល់នូវការអនុគ្រោះសិទ្ធិដល់បណ្តារដ្ឋដែលជាសមាជិកអាស៊ានថ្មីដែលនៅពេលនោះមានបួនប្រទេសរួមមាន កម្ពុជា ឡាវ មីយ៉ានម៉ា និងវៀតណាម ដើម្បីបង្កើនការចូលរួមសមាហរកម្មសេដ្ឋកិច្ចឲ្យបានកាន់តែខ្លាំងជាងនេះតាមរយៈជំនួយបច្ចេកទេស សមត្ថភាព សិទ្ធិទទួលបានព័ត៌មានស្តីពីគោលនយោបាយវិនិយោគផ្សេងៗ។

### លក្ខខណ្ឌតម្រូវសម្រាប់ប្រទេសសមាជិក

ភាគីនីមួយៗត្រូវផ្សព្វផ្សាយជាសាធារណៈ ឬផ្តល់នូវច្បាប់ បទប្បញ្ញត្តិ នីតិវិធី និងគោលការណ៍ណែនាំរដ្ឋបាលអំពីការអនុវត្តជាទូទៅទាក់ទងនឹងការវិនិយោគ ក៏ដូចជាកិច្ចព្រមព្រៀងវិនិយោគអន្តរជាតិទាំងឡាយរបស់ខ្លួនតាមការស្នើសុំរបស់ភាគីជាសមាជិកផ្សេងទៀត។ ជាមួយគ្នានេះដែរកម្ពុជាបាននឹងកំពុងជម្រុញការអនុវត្តនីតិវិធីផ្ទៃក្នុងរបស់ខ្លួនដើម្បីឆ្លើយតបលក្ខខណ្ឌតម្រូវឲ្យទាន់ពេលវេលា។

កិច្ចព្រមព្រៀងនេះ មានចំនួន ៣០មាត្រា និងចំនួន ២ ឧបសម្ព័ន ហើយការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះដរាបណាភាគីនីមួយៗបានជូនដំណឹងជាលាយលក្ខណ៍អក្សរដល់បណ្តាភាគីផ្សេងទៀតបន្ទាប់ពីការបញ្ចប់នីតិវិធីផ្ទៃក្នុងរបស់ខ្លួនចប់សព្វគ្រប់ហើយ។

### តើកម្ពុជាយើងនឹងទទួលបានផលវិជ្ជមានអ្វីខ្លះ?

កិច្ចព្រមព្រៀងនេះបាននិងកំពុងជំរុញឲ្យមានការវិនិយោគកើនឡើងបន្ថែមទៀត តាមរយៈកិច្ចសហ-ប្រតិបត្តិការក្នុងការជំរុញសកម្មភាពវិនិយោគនិងបង្កើនការយល់ដឹងក្នុងទំនាក់ទំនងវិនិយោគរវាងគូភាគីហើយ

ព្រមទាំងផ្តល់នូវកិច្ចសម្រួលវិនិយោគរវាងគូភាគីតាមរយៈការបង្កើតបរិយាកាសដែលចាំបាច់សម្រាប់ការវិនិយោគតាមគ្រប់រូបភាព ការធ្វើសាមញ្ញកម្មនីតិវិធីសម្រាប់ដាក់ពាក្យសុំវិនិយោគនិងការអនុម័តនានា ការជំរុញឲ្យមានការផ្សព្វផ្សាយព័ត៌មានវិនិយោគនិងការបង្កើតឲ្យមានមជ្ឈមណ្ឌលវិនិយោគច្រកចេញ-ចូលតែមួយនៅតាមរដ្ឋភាគីម្ចាស់ផ្ទះ។

ក្នុងនាមជាសមាជិកម្នាក់នៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ កម្ពុជាក៏នឹងទទួលបានផលជាវិជ្ជមានសម្រាប់សេដ្ឋកិច្ចរបស់ខ្លួនផងដែរ ដោយកម្ពុជានឹងបង្កើនលទ្ធភាព ទទួលបាននូវការវិនិយោគដោយផ្ទាល់ពីវិនិយោគិនមកពីប្រទេសឥណ្ឌា។

**តើកម្ពុជានឹងត្រូវប្រឈមអ្វីខ្លះ ហើយយើងនឹងត្រូវត្រៀមអ្វីបន្តទៀតនៅពេលកិច្ចព្រមព្រៀងនេះចូលជាធរមាន?**

តាមរយៈការប្រជុំបច្ចេកទេសអន្តរក្រសួងយើងសង្កេតឃើញថាកិច្ចព្រមព្រៀងមិនមានផលប៉ះពាល់ជាអវិជ្ជមានដល់កម្ពុជាទេប៉ុន្តែវាបានជួយទាក់ទាញវិនិយោគបន្ថែមពីប្រទេសឥណ្ឌាមកកាន់កម្ពុជាច្រើននិងប្រសើរជាងមុនក្នុងនាមជាសមាជិកអាស៊ាន។ ទោះជាយ៉ាងណាក៏ដោយ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាក្នុងនាមរាជរដ្ឋាភិបាលនឹងរៀបចំ (Reservation List) ដើម្បីបង្ហាញដល់ថ្នាក់ដឹកនាំបន្ទាប់ពីកិច្ចព្រមព្រៀងចូលជាធរមានដើម្បីផ្តល់ជំនឿចិត្តនិងផ្តល់ការការពារផលប៉ះពាល់ជាអវិជ្ជមានណាមួយមកលើសេដ្ឋកិច្ចកម្ពុជា។លើសពីនេះទៅទៀត វិនិយោគិនកម្ពុជាគួរចាប់ផ្តើមសិក្សាស្វែងយល់ពីវប្បធម៌ ទំនៀមទំលាប់ ប្រពៃណីរបស់ឥណ្ឌានិងត្រៀមខ្លួនរួចជាស្រេចដើម្បីធ្វើការជាមួយរាជរដ្ឋាភិបាលកម្ពុជាក្នុងការទាក់ទាញនិងស្វាគមន៍វិនិយោគផ្ទាល់ពីប្រទេសឥណ្ឌា។

*ក.ស.វ. - ក្រុម ២*

**<u>គំនិតគួរចងចាំ</u>**

« កំណាញ់និងការឱ្យទាន សេចក្តីសុខនិងសេចក្តីទុក្ខ ស្រឡាញ់និងស្អប់ បុគ្គល អាចយកប្រមាណសេចក្តីបាន ដោយយកខ្លួនអាត្មាជាគ្រឿងឧបមា។ »

ស្រីហិតោបទេស - ភិក្ខុ ប៉ាង ខាត់ វិរិយបណ្ឌិតោ ១៩៥៤

## ១- ឥណ្ឌានឹងបាត់បង់ផលប្រយោជន៍ច្រើនពី Quad

អូស្ត្រាលីនិងអាមេរិកទំនងជាជំរុញរបៀបវារៈថ្មីនៅក្នុងកិច្ចប្រជុំតូក្យូ Quad បន្ទាប់ពីការសន្យាដែលមិនបានរំពឹងទុករបស់ប្រទេសចិនក្នុងគោលបំណងដើម្បីឈានដល់កម្រិតអតិបរមាឥន្ធនៈហ្វូស៊ីលមុនឆ្នាំ ២០៣០ និងសេដ្ឋកិច្ចអព្យាក្រឹតកាបូនមុនឆ្នាំ ២០៦០ ។

ដូច្នេះសន្តិសុខថាមពលនឹងក្លាយជាបញ្ហាថ្មីបំផុត ចេញនៅក្នុងកិច្ចប្រជុំ Quad នេះ។ ការពិភាក្សាទំនងជានឹងត្រូវធ្វើឡើងលើវិធីដើម្បីដោះស្រាយរួមគ្នាជាមួយការសម្រេចចិត្តរបស់ចិនក្នុងការឆ្ពោះទៅរកសេដ្ឋកិច្ចអព្យាក្រឹតកាបូនក្នុងរយៈពេលបួនទសវត្សរ៍ខាងមុខនេះ។

**យុទ្ធសាស្ត្ររបស់អាមេរិក៖**

ប្រទេសឥណ្ឌាគឺជាអ្នកប្រើប្រាស់ឥន្ធនៈផូស៊ីលធំលំដាប់ទី២ នៅលើពិភពលោក។ វាគឺជាអ្នកនាំចូលធ្យូងថ្មឧស្ម័នធម្មជាតិនិងប្រេង។ស្រដៀងគ្នានេះដែរប្រទេសជប៉ុនក៏ជាអ្នកប្រើប្រាស់សំខាន់និងជាអ្នកនាំចូលប្រេងសាំងសុទ្ធផងដែរ។ ផ្ទុយទៅវិញសហរដ្ឋអាមេរិកនិងអូស្ត្រាលី គឺជាអ្នកនាំចេញឥន្ធនៈហ្វូស៊ីលសុទ្ធ។

ប្រទេសចិនបានប្រកាសថា ខ្លួននឹងឈានដល់ចំណុចកំពូលនៃការប្រើប្រាស់ថាមពលធ្យូងថ្ម និងប្រេងឥន្ធនៈនៅមុនឆ្នាំ២០៣០។បន្ទាប់មកប្រទេសនេះនឹងបន្តជំនួសឥន្ធនៈទាំងនោះដោយថាមពលស្អាតនិងឈានដល់សេដ្ឋកិច្ចអព្យាក្រឹតកាបូនមុនឆ្នាំ ២០៦០។ ដូច្នេះប្រជាជនចិននឹងកាត់បន្ថយការនាំចូលធ្យូងថ្ម និងប្រេងឆៅភ្លាមៗនៅពេលដែលការផ្គត់ផ្គង់ក្នុងស្រុកកើនឡើង។ នោះមានន័យថាសហរដ្ឋអាមេរិកនិងអូស្ត្រាលីត្រូវតែស្វែងរកទិសដៅថ្មីសម្រាប់ការនាំចេញធ្យូងថ្មនិងប្រេង។សហរដ្ឋអាមេរិកក៏ចង់ឈានដល់ការព្រមព្រៀងគ្នាមួយក្នុងចំណោមសមាជិក Quad ស្តីពីការជំរុញឱ្យប្រទេសចិន វិលត្រឡប់មករក្សាទុកឧស្សាហកម្មយានយន្តដ៏ធំរបស់ខ្លួន ដែលផលិតផលរបស់ពួកគេដំណើរការលើឥន្ធនៈហ្វូស៊ីល។

ដូច្នេះឥណ្ឌានិងជប៉ុនគឺជាជម្រើសធម្មជាតិសម្រាប់ការនាំចេញ ប្រេងឆៅនិងធ្យូងថ្មរបស់អាមេរិក និងដៃគូសម្រាប់សន្សំឧស្សាហកម្មរថយន្តរបស់ខ្លួន។

**ដំណឹងអាក្រក់សម្រាប់ប្រជាជនឥណ្ឌា៖**

វាជាដំណឹងអាក្រក់សម្រាប់អ្នកប្រើប្រាស់ឥន្ធនៈហ្វូស៊ីលនៅឥណ្ឌា។ សហរដ្ឋអាមេរិកទំនងជាបង្ខំឱ្យឥណ្ឌានិងជប៉ុន ទិញប្រេងឆៅនិងធ្យូងថ្មរបស់ខ្លួនក្នុងបរិមាណច្រើន ខណៈអូស្ត្រាលីក៏ត្រូវបានគេរំពឹងថានឹងទទួលបានចំណែកនៃទីផ្សារនោះផងដែរ។ឥណ្ឌាបាននឹងកំពុងនាំចូលប្រេងថោកពីអ៊ីរ៉ង់ដោយសារអាមេរិកបានលើកលែងឥណ្ឌាពីការដាក់ទណ្ឌកម្មប្រឆាំងអ៊ីរ៉ង់។ ប៉ុន្តែឥណ្ឌាបានបញ្ឈប់ការនាំចូលប្រេងអ៊ីរ៉ង់ ចាប់តាំងពីខែឧសភាឆ្នាំ ២០១៩ បន្ទាប់ពីអាមេរិកដកការលើកលែង។

សហរដ្ឋអាមេរិកទំនងជាបង្ខំឱ្យឥណ្ឌានាំចូលប្រេងនិងធ្យូងថ្មរបស់ខ្លួនតាមរយៈកិច្ចព្រមព្រៀងរយៈពេលវែង។ក្នុងស្ថានភាពនោះឥណ្ឌានឹងត្រូវកាត់បន្ថយការនាំចូលរបស់ខ្លួនពីបណ្តាប្រទេសអារ៉ាប់។សហរដ្ឋអាមេរិកអាចនឹងដាក់សម្ពាធឥណ្ឌាឱ្យយល់ព្រមលើយន្តការទិញជាក់លាក់មួយដែលនឹងមិនរងផលប៉ះពាល់ដោយការប្រែប្រួលតម្លៃទីផ្សារប្រចាំថ្ងៃ។

ជាលទ្ធផលប្រជាជនឥណ្ឌានឹងត្រូវចំណាយច្រើនសម្រាប់ផលិតផលប្រេងរបស់អាមេរិកច្រើនជាងពេលបច្ចុប្បន្ននេះសម្រាប់ប្រេងអារ៉ាប់។ ប្រសិនបើឥណ្ឌាបដិសេធសំណើរបស់អាមេរិកនោះទីក្រុងវ៉ាស៊ីនតោននឹងប្រើវិធានការ សងសឹកដូចដែលធ្លាប់បានធ្វើកន្លងមក។

ដូច្នេះអ្នកប្រើប្រាស់ឥណ្ឌានឹងត្រូវបង់ថ្លៃយុទ្ធសាស្ត្រនៃការ ស្រឡាញ់ហានិភ័យរបស់រដ្ឋមន្ត្រីក្រសួងការបរទេសឥណ្ឌាដើម្បីទៅរកសម្ព័ន្ធភាពជាមួយសហរដ្ឋអាមេរិក-ប្រទេសឥណ្ឌានឹងបាត់បង់ច្រើនជាងការទទួលបានពី Quad នាពេលអនាគត។

ដោយ នរ៉ាណាឫទ្ធិ អានន្ទជាយ៉ាត

## ២- សម្តេចតេជោ ហ៊ុន សែន ប្រកាន់នយោបាយចម្រុះពណ៌

ថ្មីៗនេះ **សម្តេចតេជោ ហ៊ុន សែន** ប្រមុខរាជរដ្ឋាភិបាលកម្ពុជា បានប្រកាសប្រាប់ពិភពលោកស្តីអំពីនយោបាយការបរទេសដ៏ប្រពៃថ្លៃថ្លាថា " កម្ពុជាប្រកាន់នយោបាយចម្រុះពណ៌ " ក្នុងទំនាក់ទំនងគ្រប់បណ្តាប្រទេសទាំងអស់លើពិភពលោក។ តែទន្ទឹមនឹងនេះកម្ពុជាក៏ពុំអាចគេចផុតពីព្យុះកំណាចនៃភូមិសាស្ត្រនយោបាយដែលបង្កឡើងពីប្រទេសមហាអំណាចបានទេ។ ព្រោះមានមហាអំណាចនិងសម្ព័ន្ធមិត្តខ្លះដោយសារតែដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួននៅបន្តការអនុវត្តប្រើប្រាស់រូបភាពស្តង់ដារពីរក្រោមលេសលិទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស។

នយោបាយ ចម្រុះ ពណ៌ " Multi-Colored Political " គឺជានយោបាយពុំមានការរើសអើងនិន្នាការនយោបាយ រវាងប្រទេស ឬមហាអំណាចណាមួយឡើយ។ ពោលមិនថា ចិន អាមេរិក រុស្ស៊ី អឺរ៉ុប ឬបណ្តាប្រទេសនានាលើពិភពលោកគឺជាមិត្តកម្ពុជាទាំងអស់។ម៉្យាងវិញទៀតកម្ពុជាជាសមាជិកអាស៊ានបានបង្ហាញយ៉ាងច្បាស់ថា " កម្ពុជាប្រកាន់នយោបាយចម្រុះពណ៌ " យ៉ាងស្រស់បំព្រង។ ព្រោះអាស៊ាន គឺមានយន្តការអាស៊ានបូកបណ្តាប្រទេសធំៗ និងបណ្តាប្រទេសនានាលើពិភពលោក មានដូចជាអាស៊ានបូកចិន ជប៉ុន កូរ៉េ អូស្ត្រាលី នូវែលសេឡង់ ឥណ្ឌានិងសហរដ្ឋអាមេរិកជាដើម ។

ស្ថិតក្នុងបរិបទនយោបាយចម្រុះពណ៌នេះទៀតសោតកម្ពុជាធ្វើជាម្ចាស់ផ្ទះកិច្ចប្រជុំអាស៊ី-អឺរ៉ុប( Asem13 ) នៅថ្ងៃទី២៥-២៦ ខែវិច្ឆិកា ឆ្នាំ២០២១ខាងមុខនេះ ដោយមានការចូលរួមពីប្រមុខរដ្ឋ-ប្រមុខរាជរដ្ឋាភិបាលមកពីទ្វីបអាស៊ី-អឺរ៉ុបជាង៥០ប្រទេស គឺរឹតតែបង្ហាញយ៉ាងច្បាស់ថែមទៀតពីស្នូននយោបាយចម្រុះពណ៌ទាំងខាងសេដ្ឋកិច្ច និងទំនាក់ទំនងការបរទេសយ៉ាងប្រពៃបំផុត។

ជាក់ស្តែងកម្ពុជាបានបើកទូលាយទីផ្សារសេរីទៅលើក្រុមហ៊ុនបច្ចេកវិទ្យាយក្សៗរបស់ប្រទេសមហាអំណាចទាំងអស់ តួយ៉ាងដូចក្រុមហ៊ុនបច្ចេកវិទ្យាអាមេរិកកាំង មានដូចជា Facebook, Google, Microsoft ក្រុមហ៊ុនបច្ចេកវិទ្យាចិន មានដូចជា Wechat TikTok ... ក្រុមហ៊ុនបច្ចេកវិទ្យារុស្ស៊ី មាន Telegram ជាដើម។ បានន័យថា កម្ពុជាជាទីផ្សារក្នុងការប្រកួតប្រជែងដោយសេរីរបស់មហាអំណាចទាំងធំទាំងតូច។ នេះបានបង្ហាញថាកម្ពុជាពុំមែនជាប្រទេសចំណុះឱ្យប្រទេសមហាអំណាចណាមួយឡើយ។

ស្ថិតក្នុងបរិការនេះ សព្វថ្ងៃដោយសារព្យុះកំណាចភូមិសាស្ត្រនយោបាយមានការប្រកួតប្រជែងគ្នារវាងសហរដ្ឋអាមេរិកនិងចិននោះ យើងឃើញថាសហរដ្ឋអាមេរិកក៏ដូចជាសម្ព័ន្ធមិត្តខ្លះ តែងរកលេសចោទប្រកាន់កម្ពុជាម្តងហើយម្តងទៀតថាកម្ពុជាងាកទៅចិន ដោយបោះបង់ចោលអាមេរិក ឬក៏ថាកម្ពុជាពុំមានលទ្ធិប្រជាធិបតេយ្យនិងការគោរពសិទ្ធិមនុស្សជាដើម។

បិតក្នុងបំណងបំលែងរូបភាពពីការប្រកាន់នយោបាយចម្រុះពណ៌របស់កម្ពុជាទៅជានយោបាយពណ៌តែមួយ ដើម្បីធ្វើជាលាតត្រដាងឱ្យឃើញកម្ពុជាកំពុងមានបញ្ហាលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្សនោះ ត្រង់ចំណុចនេះ ដែលសម្ព័ន្ធមិត្តអាមេរិកាំងកាលពីកន្លងទៅនេះ ប្រទេសស៊ុយអែត បានចេញមុខធ្វើជាដើរតួដកទូតចេញពីកម្ពុជា គឺចង់ទាញសញ្ញាណមួយប្រាប់ថាទំនាក់ទំនងទ្វេភាគីរវាងកម្ពុជានិង

ស៊ុយអែត កំពុងតែមានបញ្ហាលិទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស។ ដូច្នេះហើយបានជាមានការសម្រេចចិត្ត បែបនេះ។

ចំពោះទង្វើប្រទេសស៊ុយអែតរបៀបនេះ គឺគ្រាន់តែជាលេសបញ្ជូនសារទៅដល់ប្រទេសដទៃទៀតឱ្យមើលឃើញថា គាត់ជាប្រទេសមួយ ដែលនាំមុខគេក្នុងការគោរពលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ។ តែអ្វីដែលគួរឱ្យអស់សំណើចនោះ ប្រទេសស៊ុយអែតភ្លេចគិតឬពុំបានសម្លឹងមើលប្រទេសថៃដែលបានធ្វើរដ្ឋប្រហារយោធាច្រើនស្ទើររាប់ពុំអស់ ក៏ដូចជាប្រទេសវៀតណាមដែលប្រកាន់របបនយោបាយកុម្មុយនីស្តនោះទេ។ តើនេះមិនហៅថាប្រទេសមហាអំណាចឬសម្ព័ន្ធមិត្តខ្លះនៅបន្តប្រើប្រាស់ការអនុវត្តរូបភាពស្តង់ដារពីរក្រោមលេសលិទ្ធិប្រជាធិបតេយ្យនិងការគោរពសិទ្ធិមនុស្សទេឬអ្វី?

បើដូច្នេះសហរដ្ឋអាមេរិក និងសម្ព័ន្ធមិត្តខ្លះដោយសារតែផលប្រយោជន៍ផ្ទាល់ខ្លួន ពុំគួរយកកម្ពុជាធ្វើជាសមរភូមិ ភូមិសាស្ត្រនយោបាយនាំឱ្យកម្ពុជារងគ្រោះនោះទៀតទេ។ ព្រោះ ប្រមុខរាជរដ្ឋាភិបាល សម្តេចតេជោ **ហ៊ុន សែន** បានបញ្ជាក់រួចហើយ ថា " កម្ពុជាប្រកាន់នយោបាយចម្រុះពណ៌" ៕

ដោយ វត្ត សណ្តាប់

**<u>គំនិតគួរពិចារណា</u>**

« វិជ្ជានាំឱ្យមានវិន័យ វិន័យនាំឱ្យបានសេចក្តីថ្លៃថ្នូរ សេចក្តីថ្លៃថ្នូរនាំឱ្យបានទ្រព្យសម្បត្តិ ទ្រព្យសម្បត្តិនាំឱ្យបានធម៌ ធម៌ដឹកនាំឱ្យបានសេចក្តីសុខ។ »

លោកន័យសាស្ត្រ - មាស ព្រេង ១៩៥៧

# ១- ការវិវត្តនៃប្រព័ន្ធទឹកសាប និងប្រវត្តិនៃ វិស័យជលផលទឹកសាបកម្ពុជា (តចប់)

តារាងលេខ២. ការចំណាយ និងទុនវិនិយោគនៃអាជីវកម្មនេសាទទឹកសាប (១៩៩៧-៩៨) ដែលធ្វើអង្កេត

| ប្រភេទនេសាទ | ចំណាយប្រចាំឆ្នាំ ($) | ទុនបង្វិល ឬទុនដំណើរការសុទ្ធ ($) | ចំណាយសុទ្ធលើទ្រព្យសកម្មថេរ ($) | ទុនវិនិយោគសរុប ($) |
|---|---|---|---|---|
| ឡូត៍នេសាទនៅបឹងទន្លេសាប | ៣.៥៨២.៩០០ | ១.៤៣៣.១៦០ | ១.០៨១.៧៤០ | ២.៥១៤.៩០០ |
| ឡូត៍នេសាទក្រៅបឹងទន្លេសាប | ១០.៦៥៥.០៥០ | ៣.៧២៩.២៩២ | ៩.៣៥៥.៥៧០ | ១៣.៩៨៤.៨៦២ |
| ឡូត៍នេសាទ ដាយត្រី | ៩៥៣.៧៥៦ | ២៨៦.១៥១ | ១.៣៥៣.៤៦៨ | ១.៦៣៩.៦១៩ |
| ឡូត៍នេសាទនៅមេគង្គលើ | ២៥.៩៤២ | ៥.១៨០ | ៤៥.៧០៣ | ៥០.៨៨៣ |
| លប-ណាំរ នៅបឹងទន្លេសាប | ៦.៥៩៥.៩៣២ | ១.៩៧៨.៨៥១ | ៤.៧៣៩.១៧៥ | ៦.៧១៨.០២៦ |
| អួនអួស | ៦.៧៦៨.០៧៥ | ១.០១៥.២៥០ | ៦.៨៨៦.៦៥០ | ៧.៩០១.៩០០ |
| អួនហ៊ុំ | ១០.១៥១.៤៣០ | ២.០៣០.២៨៦ | ៧.៧២៣.៦៦៤ | ៩.៧៥៣.៩៥០ |
| សរុបរួម | ៣៨.៧៣៣.១២០ | ១០.៥៧៨.១៧០ | ៣១.១៨៥.៩៨១ | ៤២.៥៦៤.១៤០ |

កំណត់ចំណាំ: អត្រាប្តូរប្រាក់នៅឆ្នាំស្រាវជ្រាវ១៩៩៧-៩៨ គឺ ៣,៥០០ - ៣,៨០០៛ ស្មើនឹង១ដុល្លាអាមេរិក

ដោយសារការអង្កេតនេះមិនបានធ្វើលំអិតទៅដល់ការធ្វើអាជីវកម្មនៃប្រភេទនេសាទខ្លះដែលមានចំនួនអង្គភាពនេសាទតិចហើយធ្វើសកម្មភាពរយៈពេលខ្លីដូចជា ឡូត៍ដាយបង្កង ឡូត៍ឆ្នេរខ្សាច់ ការនេសាទចល័ត (ម៉ាញ់ នាម និងឆែវ៉ាជាដើម) ដែលប៉ាន់ស្មានថាអាចក្តាប់យកប្រហែល ២០% នៃ ចំណាយសរុបប្រចាំឆ្នាំ ដូច្នេះការប៉ាន់ស្មានលើមូលដ្ឋានច្បាស់លាស់អាចធ្វើបានដូចខាងក្រោម៖

- ការចំណាយសរុបប្រចាំឆ្នាំ អាចកើនឡើងដល់ចំនួន **៤៧លានដុល្លាអាមេរិក**
- ទុនបង្វិលឬទុនដំណើរការសុទ្ធអាចកើនឡើងដល់ចំនួន **១២លានដុល្លាអាមេរិក**
- ការចំណាយសុទ្ធលើទ្រព្យសកម្មថេរអាចកើនឡើងដល់ចំនួន **៣៧លានដុល្លាអាមេរិក**

ដោយសារការនេសាទទឹកសាបជាលក្ខណៈសេដ្ឋកិច្ចទូទាំងប្រទេសត្រូវចំណាយលើការបង់ពន្ធជូនរដ្ឋចំនួន **៣លានដុល្លាអាមេរិក**[44] សម្រាប់រដូវនេសាទឆ្នាំ១៩៩៧-៩៨ជាបន្ថែមទៀតនោះធ្វើឱ្យ៖

(១) ការចំណាយប្រចាំឆ្នាំសរុបសុទ្ធ កើនឡើងដល់ចំនួន **៥០លានដុល្លាអាមេរិក** និង

(២) ទុនវិនិយោគសរុប កើនឡើងដល់ចំនួន **៥៦លានដុល្លាអាមេរិក**។

ចំណូលពីការនេសាទត្រីទឹកសាបជាលក្ខណៈសេដ្ឋកិច្ច ផ្អែកទៅលើទិន្នផលត្រីដែលដកស្រង់ពីការ

[44] ក្រសួងហិរញ្ញវត្ថុ,១៩៩៨. របាយការណ៍ចំណូលថវិកាឆ្នាំ១៩៩៨

ប្រកាសរបស់អ្នកនេសាទមានបរិមាណចំនួនពី៦០.០០០ ទៅ៧០.០០០តោន ឯតម្លៃត្រីជាក់ស្តែងនៅមូលដ្ឋានជាមធ្យមនៅពេលនោះគឺ០,៥ដុល្លាអាមេរិកក្នុងមួយគីឡូដូច្នេះចំណូលសរុបមានប្រហែលពី៣០.០០០.០០០ ទៅ៣៥.០០០.០០០ដុល្លាអាមេរិកក្នុងមួយរដូវនេសាទឆ្នាំ១៩៩៧-៩៨។បើផ្អែកលើទិន្នផលដែលដង្ហៅនេសាទរាយការណ៍នៅក្នុងស្ថិតិជលផលឃើញថា មុខរបរនេសាទទឹកសាបមាន ការខាតបង់ប្រហែលពី ~២៦%ទៅ ~៣៥%ក្នុងមួយឆ្នាំ ដែលមានន័យថារបរនេះត្រូវតែក្រឡាប់ចាក់មិន អាចបន្តសកម្មភាពបានឡើយ ប៉ុន្តែជាក់ស្តែងវិស័យនេះនៅតែមានដំណើរការជាប់ជារហូតមក និងបាន បន្តទៅមុខទៀតរហូតដល់រាជរដ្ឋាភិបាលប្រកាសបញ្ឈប់ការធ្វើអាជីវកម្មកាលពីឆ្នាំ២០១២ ។

បើធ្វើការគណនាដោយផ្អែកលើទិន្នផលត្រី ដែលគ្រោងការណ៍គ្រប់គ្រងនេសាទទឹកសាបកម្ពុជា បានស្រាវជ្រាវរកឃើញថាមានចំនួនពី **១៣០.០០០** ទៅ**១៨០.០០០តោន**នោះ ចំណូលពីការនេសាទ ទឹកសាបជាលក្ខណៈសេដ្ឋកិច្ច អាចមានចំនួនពី **៦៥.០០០.០០០** ទៅ **៩០.០០០.០០០ដុល្លាអាមេរិក** ក្នុងមួយរដូវនេសាទឆ្នាំ១៩៩៧-៩៨។

ប្រសិទ្ធភាពសេដ្ឋកិច្ចជលផលទឹកសាប ដោយផ្អែកលើទិន្នន័យដែលបានស្រាវជ្រាវរកឃើញ ដោយគ្រោងការណ៍គ្រប់គ្រងនេសាទទឹកសាបកម្ពុជាត្រូវបានវិភាគដូចក្នុងតារាងលេខ៣ខាងក្រោម៖

**តារាងលេខ៣. ប្រសិទ្ធភាពសេដ្ឋកិច្ចនេសាទទឹកសាប (ចំណេញឬខាត) និងអត្រាឆ្លើយតបទៅនឹងទុនវិនិយោគ**

| ចំណូលសរុប ($) | ចំណាយសរុបសុទ្ធ ($) | ចំណេញសុទ្ធ ឬខាត (ចំណូល--ចំណាយ) | ទុនវិនិយោគសរុប ($) | អត្រាឆ្លើយតបទៅនឹងទុនវិនិយោគ (%) (ចំណេញ/ទុនវិនិយោគសរុប) |
|---|---|---|---|---|
| **៦៥.០០០.០០០ (កំរិតអប្បបរិមា)** | **៥០.០០០.០០០** | **+ ១៥.០០០.០០០** | **៥៦.០០០.០០០** | **~២៦% (ការវិនិយោគដែលទទួលបានផលតិច)** |
| **៩០.០០០.០០០ (កំរិតអតិបរិមា)** | **៥០.០០០.០០០** | **+ ៤០.០០០.០០០** | **៥៦.០០០.០០០** | **~៧១% (ការវិនិយោគដែលគួរឲ្យពេញចិត្ត)** |

ការវិភាគខាងលើបានបង្ហាញថា ទិន្នផលត្រីបានពីការនេសាទទឹកសាបជាលក្ខណៈសេដ្ឋកិច្ច ដែលស្រាវជ្រាវតាមវិធីសាស្ត្រវិទ្យាសាស្ត្រមានភាពសមហេតុផលជាងការប្រកាសរបស់ដង្ហៅនេសាទដែលអាចយកជាមូលដ្ឋានក្នុងការវាយតម្លៃស្ថានភាពសេដ្ឋកិច្ចជលផលទូទាំងប្រទេសបានដោយគ្រាន់តែបូកផលនេសាទជាលក្ខណៈគ្រួសារមិនជាប់ពន្ធប្រមាណ៣០%នៃផលនេសាទជាលក្ខណៈសេដ្ឋកិច្ចជាបន្ថែមទៀត។ដូច្នេះផលត្រីទឹកសាបជាសរុបក្នុងកំរិតអប្បបរិមា អាចមានចំនួន [១៣០.០០០តោន+ (១៣០.០០០ x ៣០%)] = ១៦៩.០០០តោន ដែលមានតម្លៃប្រហែល **~៨៥លានដុល្លាអាមេរិក** និងក្នុងកំរិតអតិបរិមា អាចមានចំនួន [១៨០.០០០ + (១៨០០០០x ៣០%)] = ២៣៤.០០០តោន ដែលមានតម្លៃប្រហែល **~១១៧លានដុល្លាអាមេរិក** នៅអំឡុងឆ្នាំដែលស្រាវជ្រាវនោះ។

### ៩.២.២. ស្ថានភាពសង្គមសេដ្ឋកិច្ចជលផល

ភាពសម្បូរបែបនៃត្រីទឹកសាបកម្ពុជា បានជំរុញឲ្យគណៈកម្មការទន្លេមេគង្គអន្តរជាតិវាយតម្លៃថា តម្រូវការប្រើប្រាស់បរិភោគរបស់ប្រជាជនកម្ពុជាម្នាក់ៗក្នុងមួយឆ្នាំមានប្រហែល៤.២៧០,៥ក្រសម្រាប់សេចក្តី

ត្រូវការអាហារូបត្ថមអប្បបរិមាមួយ នាដើមទសវត្សឆ្នាំ៩០[45] (ប្រូតេអ៊ីនបរិភោគដែលបានពីប្រភព សាច់សរុបមាន ៣៣,៣% ក្នុងនោះ ៧៥%បានមកពីត្រី)។ ការស្រាវជ្រាវវិទ្យាសាស្ត្រមួយ សម្រាប់បំពេញ និក្ខេបបទថ្នាក់អនុបណ្ឌិតរបស់អ្នកនិពន្ធនៅចុងឆ្នាំ១៩៩២ បានរកឃើញថា នៅតាមវាលស្រែ នៃតំបន់ដែលមិនជាប់ទាក់ទងទៅនឹងដែននេសាទនៃបឹងទន្លេសាប ទំនាបទន្លេមេគង្គ ទំនាបទន្លេសាប និងទំនាបទន្លេបាសាក់ផងនោះ ក៏អ្នកស្រុកនៅទីនោះអាចចាប់ត្រីពីធម្មជាតិ និងទិញពីផ្សាយកមក បរិភោគបានប្រហែល ពី៣០គក្រទៅ៤៥គក្រ/ឆ្នាំដែរ (ស្មើនឹង៣០៤៦,៥ក្រ ទៅ៣៨៦២,១ក្រ/ឆ្នាំ) គឺប្រហែល ពី៧១,៣%ទៅ៩០,៤%នៃតម្រូវការដែលបានលើកឡើងខាងលើ[46]។នៅអំឡុងចុងទសវត្សឆ្នាំ៩០មានការស្រាវជ្រាវសង្គមសេដ្ឋកិច្ចមួយដែលដឹកនាំធ្វើដោយអ្នកជំនាញនៃគ្រោងការណ៍គ្រប់គ្រង នេសាទត្រីទឹកសាបកម្ពុជា ដែលបានរកឃើញថាប្រជាជនដែលរស់នៅជិតដែលនេសាទសំខាន់ៗដូចជានៅជុំវិញបឹងទន្លេសាបនិងនៅតាមទីទំនាបទន្លេមេគង្គ ទំនាបទន្លេសាប និងទំនាបទន្លេបាសាក់ អាចបរិភោគត្រីទឹកសាបបានរហូតដល់ជាង៧០គក្រ/ឆ្នាំ[47]។

លទ្ធផលពីកំណើនប្រជាជន ជាពិសេសនៅតំបន់ទំនាបជាប់បឹងទន្លេបានជំរុញឲ្យការនេសាទ គ្រប់ប្រភេទបង្កើនសកម្មភាពដោយបង្កប់នូវភាពអានាធិបតេយ្យល្មើសច្បាប់កាន់តែច្រើនឡើងៗពីមួយឆ្នាំទៅមួយឆ្នាំ បង្កើតបានជាទំនាស់ រវាងអ្នកនេសាទជាលក្ខណៈសេដ្ឋកិច្ចជាប់ពន្ធ និងអ្នកនេសាទជា លក្ខណៈគ្រួសាររហូតដល់មានការកែទម្រង់ជលផលដ៏ធំមួយចាប់ពី ឆ្នាំ២០០០ដល់២០១១។ ឡូត៍នេសាទបឹងព្រែកចំនួន៥៥ឡូត៍ដាយចំនួន៣និងឡូត៍ឆ្នេរខ្សាច់ចំនួន២០ស្មើនឹង៥៤១,២០៦ហិចតា(៥៦,៧៩%)ត្រូវបានលប់ចោលជាស្ថាពរ និងជម្រុញឲ្យមានការរៀបចំធ្វើសេចក្តីព្រាងច្បាប់ជលផល ថ្មីមួយដ៏តឹងតែង ហើយដែលបានអនុម័តឲ្យប្រើប្រាស់នៅឆ្នាំ២០០៦។នាយកដ្ឋានជលផល ត្រូវបាន ប្តូរទៅជារដ្ឋបាលជលផលដែលមានថានៈស្មើនឹងអគ្គនាយកដ្ឋាននៅពេលនោះផងដែរ។

ទោះជាយ៉ាងនេះក៏ដោយសម្ពាធនេសាទបានរីករាលដាលដល់តំបន់ទន្លេមេគង្គលើដែលធ្វើឲ្យប៉ះពាល់យ៉ាងខ្លាំងដល់មេពូជត្រីសំខាន់ៗដែលពងកូននៅតំបន់ខាងលើ និងសត្វផ្សោត ដែលធ្វើឲ្យមាន ការភ្ញាក់ផ្អើលពាសពេញពិភពលោក រហូតដល់រាជរដ្ឋាភិបាលសំរេចបង្កើត តំបន់អភិរក្សសត្វផ្សោតទន្លេ មេគង្គ[48] និងត្រីមេពូជនៅខេត្តក្រចេះ និងស្ទឹងត្រែង នាឆ្នាំ២០១២។

### ៩.២.៣. ការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រជលផលសម្រាប់កិច្ចអភិរក្សសមស្រប

ក្នុងអំឡុងចុងសតវត្សទី២០ និងដើមសតវត្សទី២១ ក្រុមអ្នកវិទ្យាសាស្ត្រជលផលបានចាប់ អារម្មណ៍ដល់ការស្រាវជ្រាវស៊ីជម្រៅ ពីប្រព័ន្ធទំនាក់ទំនងអេកូឡូស៊ី ជាប់ពាក់ព័ន្ធទៅនឹងលក្ខខណ្ឌ រូបសាស្ត្រ គីមីសាស្ត្រ និងជីវសាស្ត្រ ដែលឆ្លុះបញ្ចាំងពីភាពសំខាន់នៃកន្លែងបន្តពូជពង្ស និងស៊ីចំណី គន្លងផ្លូវធ្វើបន្លាស់ទី និងជំរកសម្ងំលាក់ខ្លួននៅរដូវប្រាំង (Tana, T. S., 2000)[49] ដែលនាំទៅដល់ គម្ពើញវិទ្យាសាស្ត្រពីវដ្តជីវិតនៃប្រភេទត្រីសំខាន់ៗមួយចំនួន ដូចជា ត្រីប្រា ត្រីប៉ាសេអ៊ីជាដើម និងលក្ខខ័ណ្ឌជីវសាស្ត្ររបស់ត្រីទឹកសាប

45 Mekong Committee, 1992. Review of the Fishery Sector in the Lower Mekong Basin.
46 Touch Seang Tana, 1993. Fish Supply and Demand in Rural Svay Rieng Province, Cambodia. MSc Thesis.
47 Ahmed, M., Navy, H., Vuthy, L., and, Tiongco, M., 1998. Socio-economic Survey in freshwater system of Cambodia.
48 អនុក្រឹត្យស្តីពីការបង្កើតតំបន់អភិរក្សសត្វផ្សោតទន្លេមេគង្គ លេខ១៥៥អនក្រ បក ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១២
49 Tana, T. S., 2002. The Critical Role of the Mekong and Tonle Sap Corridor for the Tonle Sap Lake Ecology and the Importance of the Waterway Corridor Within and Between the Ecosystem of the Inland Wetland in Cambodia. Proceeding of the Tonle Sap Lake Biosphere Reserve Workshop in Phnom Penh.

(Tana, T. S., 2008)[50] ដែលអាចយកទៅរៀបចំជាបទបញ្ញា នេសាទដ៏មានប្រសិទ្ធភាពដើម្បីស្តារឡើងវិញនូវធនធានសំខាន់ៗដែលកំពុងរងការគំរាមកំហែងនេះ។

យ៉ាងណាក៏ដោយក៏ការគ្រប់គ្រងជលផលទឹកសាបនៅតែមានបញ្ហាទាក់ទងទៅនឹងទំនាស់ដែននេសាទរវាងអ្នកនេសាទជាលក្ខណៈសេដ្ឋកិច្ចដែលជាប់ពន្ធ និងអ្នកនេសាទគ្រួសារបំពេញការរស់នៅ។

ដោយសារភាពរាំរ៉ៃនៃការមិនយោគយល់គ្នានេះរាជរដ្ឋាភិបាលបានសម្រេចលប់ឡូត៍នេសាទចំនួន៨០ស្មើនឹង៤១២,៦៥៤ហិចតាដាក់ឲ្យទៅជាកន្លែងអភិរក្សចំនួន៩៧,៥០២ហិចតានិងទៅជាដែននេសាទគ្រួសារចំនួន៣១៥១៥២ហិចតានៅអំឡុងឆ្នាំ២០១២[51] ហើយរក្សាទុកឡូត៍ដាយមួយចំនួនឲ្យនេសាទ ដើម្បីផ្គត់ផ្គង់ត្រីធ្វើប្រហុកជូនប្រជាជនដែលនៅតំបន់គ្មានដែននេសាទ (សូមមើលរូបទី២១ និង២២)។

បច្ចុប្បន្ននៅសល់តែឡូត៍ដាយត្រីតាមដងទន្លេសាបនិងដាយបង្កងតាមទន្លេតូចក្នុងខេត្តព្រៃវែងប៉ុណ្ណោះដែលត្រូវដាក់ឲ្យដេញថ្លៃដើម្បីអនុញ្ញាតឲ្យធ្វើអាជីវកម្ម។ ភារកិច្ចរបស់រដ្ឋបាលជលផលជា ចំបង គឺទប់ស្កាត់បទល្មើសនេសាទ, ជំរុញវារីវប្បកម្ម, ត្រួតពិនិត្យគុណភាព និងចរាចរទំនិញជលផល ដែលនាំចូលប្រហែល ៥០-៦០%ពីវៀតណាមនិង១០-១៥%ពីថៃ ដើម្បីបង្គ្រប់សេចក្តីត្រូវការក្នុងស្រុក។

### ៩.២.៤. ការរៀបចំចងក្រងកាតាឡុក(បញ្ជី)ពេញលេញនៃឧបករណ៍នេសាទទឹកសាប

ការខិតខំប្រឹងប្រែងចុងក្រោយរបស់គ្រោងការណ៍គ្រប់គ្រងនេសាទទឹកសាបកម្ពុជា ដែលមានការជួយឧបត្ថមទុនពីអង្គការ DANIDA ប្រទេសដាណឺម៉ាក់ និងគណៈកម្មការទន្លេមេគង្គ MRC គឺជាការរៀបចំធ្វើកាតាឡុកពេញលេញនៃឧបករណ៍នេសាទទឹកសាបរួមទាំងទាំងឧបករណ៍ស្របច្បាប់និងហាមឃាត់ដែលកំពុងអនុវត្តនៅក្នុងប្រទេសនាបច្ចុប្បន្ននេះ។កាតាឡុកឬបញ្ជីពេញលេញនៃឧបករណ៍នេសាទទឹកសាបត្រូវបានធ្វើចប់សព្វគ្រប់ និងបោះពុម្ពផ្សព្វផ្សាយជាលើកទីមួយជាភាសាអង់គ្លេសនៅឆ្នាំ២០០៦ និងបានបកប្រែជាភាសាខ្មែរ ហើយបោះពុម្ពផ្សព្វផ្សាយជាសាធារណៈនៅឆ្នាំជាបន្ទាប់។

## ១០. បញ្ហាប្រឈមចុងក្រោយរបស់ធនធានជលផលទឹកសាប

នៅអំឡុងពេល៥០មក៤០ឆ្នាំចុងក្រោយនេះការប្រើប្រាស់ថង់ប្លាស្ទីកសម្រាប់ការវេចខ្ចប់នានាត្រូវបានគេអនុវត្តនៅគ្រប់ទីកន្លែងក្នុងប្រទេសដែលរួមទាំងនៅក្នុងប្រព័ន្ធលំនៅដ្ឋានលើទឹក និងនៅជិតជាប់ស្ទឹងព្រែក



រូបទី២១. ដាយត្រីជួរទី៩ តាមដងទន្លេសាប



រូបទី២២. ដាយនេសាទត្រីល្វិតនៅខែមករា

[50] Tana, T. S., 2008. A rational Approach to International River Management in Different Jurisdictional Context of the Greater Mekong Sub-region: Water Development Versus Biodiversity Conservation. Transborder Issues in the Greater Mekong Sub-region. Published by Mekong Sub-region Social Research Center (MSSRC), Faculty of Liberal Arts, Ubon Ratchathani University.

[51] របាយការណ៍រដ្ឋបាលជលផលឆ្នាំ២០១២

ទន្លេ បឹងបួរទាំងឡាយផង។ នៅលើគោក សំរាមចង់ប្លាស្ទិកបានបង្កើតជាបញ្ហាមួយ ដល់បរិស្ថានតែនៅអាចដោះស្រាយបាន តែនៅក្នុងទឹកវិញ សំរាមចង់ប្លាស្ទិកបានក្លាយជាបញ្ហាមួយ ដែលពិបាកដោះស្រាយបំផុតព្រោះវត្ថុមានរបស់វាបានធ្វើឲ្យប៉ះពាល់ដល់មជ្ឈដ្ឋានរស់នៅស៊ីចំណីនិងបន្តពូជរបស់ត្រីគ្រប់ប្រភេទជាពិសេសទៀតប៉ះពាល់ដល់ការនេសាទ។ការដែលគួរឲ្យព្រួយបារម្ភខ្លាំងនោះគឺសំរាមនេះនៅតែបន្តបោះចោលរាយប៉ាយពាសវាលពាសកាលនៅគ្រប់ទីកន្លែងនៃបរិស្ថានទឹកហើយជាការលំបាកបំផុតនោះគឺតើត្រូវធ្វើយ៉ាងណាដើម្បីយកវាចេញពីមជ្ឈដ្ឋាននេះ ។

ម្យ៉ាងទៀតនៅពេលដែលផលនេសាទទឹកសាបកំពុងធ្លាក់ចុះនេះ ការនេសាទដែលហាមឃាត់ ដោយច្បាប់មានសកម្មភាពកើនឡើងយ៉ាងខ្លាំង ដែលតម្រូវឲ្យមន្ត្រីអនុវត្តច្បាប់ជលផលត្រូវធ្វើការល្បាត ត្រួតពិនិត្យឃ្លាំមើលជាប់ជាប្រចាំ។ ឯអ្នកនេសាទដែលនៅធ្វើសកម្មភាព ក៏ត្រូវប្រឈមជាមួយការថយ ចុះនៃស្តុកត្រីធម្មជាតិ និងការកើនឡើងនៃសំរាមចង់ និងជបប្លាស្ទិក ដែលនៅលាយឡំជាមួយត្រីដែល ចាប់បានកាន់តែតិចទៅៗ ដែលធ្វើឲ្យជីវភាពពួកគាត់ជួបការលំបាកជាបន្តបន្ទាប់ពីមួយថ្ងៃទៅមួយថ្ងៃ។

## ១១. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

ប្រព័ន្ធទឹកសាបនៅកម្ពុជាគឺជាប្រព័ន្ធគាំទ្រការករកើតរីកចំរើននៃធនធានជលផលដ៏ពិសិទ្ធគ្មានពីរក្នុងលោក។អត្ថិភាពត្រីទឹកសាបគឺជាមូលដ្ឋាននៃការករកើតនិងការវិវត្តរីកចម្រើននៃសង្គមខ្មែរដែលប្រវត្តិសាស្រ្តបានកត់ត្រាដូច្នេះ។ត្រីទឹកសាបបានក្លាយជាអាហារប្រូតេអ៊ីនបានពីសាច់ជាមូលដ្ឋានបំផុតរបស់ខ្មែរដែលអាចកំណត់បានថាជាចំណែកមួយនៃវប្បធម៌ជាតិផងដែរ។ធនធាននេះត្រូវបានចាត់ចែងឲ្យធ្វើអាជីវកម្មបំរើសេដ្ឋកិច្ចជាតំបូង ដោយមិនចាប់អារម្មណ៍ដល់ ផលប្រយោជន៍សង្គមដែល បណ្តាលឲ្យមានទំនាស់យ៉ាងខ្លាំងរវាងការនេសាទឧស្សាហកម្មនិងការនេសាទគ្រួសារ រហូតឈានទៅ ដល់ការបែងចែកផលប្រយោជន៍ធនធានសារឡើងវិញ។ទោះជាការកែទម្រង់នៅឆ្នាំ១៨៨៤និងឆ្នាំ២០០០បានជួយដោះស្រាយបញ្ហាទាក់ទងនឹងការអភិរក្សធនធាននិងទំនាស់សង្គមបានមួយចំនួនធំក៏ដោយក៏វិស័យនេះនៅតែប្រឈមទៅនឹងការកើនឡើងនៃបទល្មើសនេសាទនិងការធ្លាក់ចុះនៃផលត្រីតាំងពីមានត្រីនាំចេញទៅបរទេសរហូតដល់នាំត្រីចូលពីបរទេសមកបំពេញសេចក្តីត្រូវការក្នុងស្រុក នាបច្ចុប្បន្នកាលនេះ។ម្យ៉ាងទៀតការកើនឡើងនៃការនេសាទដោយឧបករណ៍ឆក់ត្រីនិងស្បៃមុង នៅ គ្រប់ទីកន្លែង នឹងការកើនឡើងនៃសំរាមចង់ផ្លាស្ទិកនៅក្នុងទឹក គឺជាការគំរាមកំហែងដ៏ធំដែលអាចឲ្យវិស័យនេះរលាយរលត់ក្នុងពេលមិនយូរប៉ុន្មានខាងមុខដែលទាមទារឲ្យមានវិធានការណ៍ដ៏មានប្រសិទ្ធភាពបំផុត។ យ៉ាងណាក៏ដោយ វិស័យជលផលនៅតែជាវិស័យសំខាន់ចំពោះសង្គមខ្មែរ ទោះជាបច្ចុប្បន្ន ពុំបានរកចំណូលធំដុំជូនរដ្ឋក៏ដោយ,ព្រោះថាប្រជាជនប្រហែលជិត២លាននាក់នៅតែពឹងផ្អែកលើការនេសាទគ្រួសារដើម្បីជីវភាពរស់នៅប្រចាំថ្ងៃ។ បទពិសោធន៍នៃការចាត់ចែងធ្វើអាជីវកម្ម និងការ បង្កើតយុត្តាធិការគ្រប់គ្រងធនធានកន្លងមកបានបង្ហាញពីចំណុចល្អ និងការខ្វះខាតមិនគ្រប់ជ្រុង ជ្រោយដែលបណ្តាល ឲ្យមានផលវិបាកនាបច្ចុប្បន្ននេះ។ក្នុងទស្សនៈស្តារធនធានដ៏សំខាន់នេះឡើងវិញនៅក្នុងប្រព័ន្ធអេកូឡូស៊ីដែលមានស្រាប់នោះ, ការស្វែងយល់ជាបន្ថែមច្រើនទៀតទាក់ទងទៅនឹង លក្ខខណ្ឌធម្មជាតិ និងសង្គមត្រូវតែបានលើកទឹកចិត្តឲ្យធ្វើជាប្រចាំ ជាមួយការពិភាក្សាដ៏ទូលំទូលាយ ដោយមានការចូលរួមពីគ្រប់ មជ្ឈដ្ឋានអ្នកជំនាញទាំងក្នុងស្រុកទាំងអន្តរជាតិដើម្បីអាចរកឃើញវិធីសាស្រ្តគ្រប់គ្រងមួយដែលធានាបាននិរន្តរភាពធនធាននិងអាចទទួលយកបានពីគ្រប់មជ្ឈដ្ឋាន៕

រៀបរៀងដោយ ទូច ស៊ាងតាណា

# ២- ការប្រើប្រាស់ថាមពលអគ្គិសនីពីពន្លឺព្រះអាទិត្យ

## ១. សេចក្តីផ្តើម

ថាមពលពន្លឺព្រះអាទិត្យ ជាប្រភេទថាមពលមួយនៃថាមពលកកើតឡើងវិញ ដែលកំពុងមានសក្តានុពលសម្រាប់ប្រើប្រាស់បំពេញបន្ថែមនូវកំណើនតម្រូវការថាមពលអគ្គិសនីប្រហែល១០-២០%ក្នុងមួយឆ្នាំក្នុងការធានាការអភិវឌ្ឍសេដ្ឋកិច្ចឱ្យមាននិរន្តរភាពនៅប្រទេសកម្ពុជា ។ ដោយសារការរីកចម្រើនបច្ចេកវិទ្យាក្នុងការផលិតបន្ទះសូឡា (Solar Panel) និងអាគុយស្តុកថាមពល (battery) ប្រកបដោយគុណភាព និងប្រើបានយូរ អគ្គិសនីពីពន្លឺព្រះអាទិត្យឬដោយបន្ទះសូឡានេះកាន់តែមានតម្លៃថោក គឺប្រហែល ០,០៧ ដុល្លារអាមេរិក ឬស្មើនឹង ២០០-៣០០រៀលក្នុង១គីឡូវ៉ាត់ម៉ោង (kwh) ហើយតម្លៃនេះនឹងបន្តថយចុះទៀតរហូតដល់០,០១ ដុល្លារក្នុងឆ្នាំ ២០៥០ ។ ដោយសារតម្លៃថោកនិងងាយស្រួលតម្លើង ថាមពលពន្លឺព្រះអាទិត្យអាចប្រជែងនឹងប្រភេទថាមពលផ្សេងទៀតដូចជាអគ្គិសនីដើរដោយធ្យូងថ្មប្រេងឥន្ធនៈវារីអគ្គិសនីនិងថាមពលអាតូមិកជាដើមដែលអាចទាក់ទាញការវិនិយោគឯកជននិងក្រុមហ៊ុនផលិតថាមពលឯករាជ្យ (Independent Power Producers) ។ ផលប្រយោជន៍សំខាន់មួយទៀតគឺ ថាមពលពន្លឺព្រះអាទិត្យចាត់ទុកជាថាមពលស្អាតចូលរួមចំណែកកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់និងផលប៉ះពាល់ដល់សុខភាពមនុស្ស។ដោយមានគោលនយោបាយការគាំទ្រដល់ការផលិតថាមពលពន្លឺព្រះអាទិត្យរបស់រាជរដ្ឋាភិបាល ដែលមានក្រសួងរ៉ែនិងថាមពលជាសេនាធិការ គម្រោងអភិវឌ្ឍន៍អគ្គិសនីពន្លឺព្រះអាទិត្យខ្នាតធំ ខ្នាតមធ្យម និងកម្រិតគ្រួសារបានកំពុងរីកចម្រើនគួរឱ្យកត់សម្គាល់ក្នុងអំឡុងទសវត្សនេះ ដើម្បីបំពេញបន្ថែមនូវតម្រូវការថាមពលអគ្គិសនីនៅទីក្រុងនិងតាមជនបទ ។ មានការសិក្សាមួយចំនួនពាក់ព័ន្ធនឹងឱកាសនិងការប្រឈម ក្នុងការអភិវឌ្ឍថាមពលពន្លឺព្រះអាទិត្យនៅប្រទេសកម្ពុជា ដែលជាមូលដ្ឋានទិន្នន័យវិភាគ និងចំណេះដឹង សម្រាប់ជំរុញការអភិវឌ្ឍថាមពលនេះឱ្យកាន់តែមានប្រសិទ្ធភាព។ ដោយឡែកអត្ថបទនេះនឹងបង្ហាញអំពីការប្រឈមនិងដំណោះស្រាយមួយចំនួនសម្រាប់ការអភិវឌ្ឍប្រព័ន្ធមិនភ្ជាប់នឹងបណ្តាញអគ្គិសនីរដ្ឋ (off-gridsolarsystem) ដែលអាចបំពេញតម្រូវការប្រជាជននៅជនបទ ជាពិសេសសម្រាប់គ្រួសារដែលនៅឆ្ងាយពីបណ្តាញអគ្គិសនីរដ្ឋ។

## ២. ស្ថានភាពប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យនៅប្រទេសកម្ពុជា

### ២.១- ប្រភេទប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យ

ការសិក្សាបានបង្ហាញអំពីសក្តានុពលថាមពលពន្លឺព្រះអាទិត្យនៅកម្ពុជាដោយសារទីតាំងស្ថិតនៅតំបន់ត្រូពិកអាចទទួលកាំរស្មីព្រះអាទិត្យខ្ពស់បានប្រហែល៥,៨ម៉ោងក្នុងមួយថ្ងៃស្រូបបានកម្លាំងប្រហែល៥គីឡូវ៉ាត់ម៉ោង/១ម៉ែត្រក្រឡា (Suntrace, Dornier Group 2017) ។ យ៉ាងណាមិញ សមាសភាគប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យនៅប្រទេសកម្ពុជានៅមានកម្រិតមានប្រមាណជា០,០៥%នៅឆ្នាំ២០១៦ក្នុងចំណោមថាមពលប្រើប្រាស់ចម្រុះ រួមមានការនាំចូល២៤,៩% វារីអគ្គិសនី៣២,៣២% និងធ្យូងថ្ម៣៨,៤%។

ការប្រើប្រាស់អគ្គិសនីនៅកម្ពុជាចែកជាពីរប្រព័ន្ធ រួមមាន ប្រព័ន្ធតភ្ជាប់នឹងបណ្តាញអគ្គិសនីរដ្ឋ និងប្រព័ន្ធមិនភ្ជាប់នឹងបណ្តាញអគ្គិសនីរដ្ឋ។ ប្រព័ន្ធនីមួយៗមានប្រភេទការប្រើប្រាស់ដូចខាងក្រោម៖

ក) ប្រព័ន្ធតភ្ជាប់នឹងបណ្តាញអគ្គិសនីរដ្ឋ (on-grid) ១-ថាមពលអគ្គិសនីពន្លឺព្រះអាទិត្យខ្នាតធំ (utilty -scale photovoltaics) និង ២-ថាមពលព្រះអាទិត្យដាក់លើដំបូលអគារ (roof-top photovoltaics)

ខ) ប្រព័ន្ធមិនភ្ជាប់នឹងបណ្តាញអគ្គិសនីរដ្ឋ ៣-ថាមពលព្រះអាទិត្យខ្នាតសម្រាប់សាកអាគុយ និងបណ្តាញខ្នាតតូច (solar-battery mini-grids) ៤) ថាមពលពន្លឺព្រះអាទិត្យប្រើប្រាស់តាមផ្ទះ (solar home system) ។

ការអភិវឌ្ឍថាមពលអគ្គិសនីពន្លឺព្រះអាទិត្យខ្នាតធំ៥ បានដាក់ឱ្យដំណើរការ និងមួយចំនួនទៀតកំពុងសាងសង់ ដែលមានអានុភាពសរុប ១៦០មេហ្គាវ៉ាត់ រួមមាននៅពោធិ៍សាត់ (៣០មេហ្គាវ៉ាត់) ស្វាយរៀង (២០មេហ្គាវ៉ាត់) បាត់ដំបង (៦០មេហ្គាវ៉ាត់) កំពង់ស្ពឺ (២០មេហ្គាវ៉ាត់) និងបន្ទាយមានជ័យ (៣០មេហ្គាវ៉ាត់)។ ថ្មីៗនេះ អគ្គិសនីកម្ពុជា (EDC) បានកំពុងដំណើរការអនុម័តការសាងសង់គម្រោងវិនិយោគឯកជនពីរទៀត នៅកំពង់ឆ្នាំង (៦០មេហ្គាវ៉ាត់)និងនៅ ពោធិ៍សាត់ (៦០មេហ្គាវ៉ាត់) ដែលនឹងផ្តល់ថាមពលសរុប១២០ មេហ្គាវ៉ាត់ថែមទៀត។ការវាយតម្លៃមួយរបស់UNDP(២០១៩)ថាមពលពន្លឺព្រះអាទិត្យខ្នាតធំនឹងអាចកើនដល់៧០០មេហ្គាវ៉ាត់រហូតដល់ឆ្នាំ២០៣០ស្មើនឹង២០%នៃអានុភាពថាមពលអគ្គិសនីសរុបក្នុងប្រទេសកម្ពុជា។

## ២.២- ប្រភេទឧបករណ៍និងសម្ភារៈសម្រាប់ប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យ

ការកំណត់ឧបករណ៍និងសម្ភារៈសម្រាប់តម្លើងថាមពលពន្លឺព្រះអាទិត្យអាស្រ័យលើតម្រូវការថាមពលសម្រាប់ប្រើប្រាស់ក្នុងសកម្មភាពសេដ្ឋកិច្ច ដូចជាក្នុងកសិកម្ម (បូមទឹក) ការបំភ្លឺតាមផ្ទះ និងប្រើប្រាស់ឧបករណ៍ឬសម្ភារៈអគ្គិសនីដូចជា ទូរទស្សន៍ ឆ្នាំងភ្លើង និងទូទឹកកកជាដើម។ ជារួមសមាសភាគថាមពលពន្លឺព្រះអាទិត្យមានដូចនៅក្នុងរូប១ខាងក្រោម រួមមាន 1-បន្ទះសូឡា 2-ឧបករណ៍គ្រប់គ្រងចរន្តសាក 3-អាគុយសម្រាប់ផ្ទុកថាមពលពន្លឺព្រះអាទិត្យ និង 4-ឧបករណ៍បម្លែងចរន្តជាប់ទៅចរន្តឆ្លាស់។




ប្រភព- ប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យនិងសមាសភាគ

ដូចក្នុងរូបភាព១ថាមពលពន្លឺព្រះអាទិត្យអាចប្រើជាចរន្តជាប់ដោយភ្ជាប់ផ្ទាល់ជាមួយអាគុយ(batery) ឬប្រើជាចរន្តឆ្លាស់ដោយប្រើឧបករណ៍បម្លែង(invertor)អាស្រ័យលើឧបករណ៍ឬបរិក្ខារអគ្គិសនីដូចជាអំពូលគ្រឿងអេឡិចត្រូនិក ទូរទស្សន៍ដែលអាចប្រើជាមួយចរន្តជាប់ ឬចរន្តឆ្លាស់។

## ២.៣- តម្លៃប្រើប្រាស់ប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះ

បច្ចុប្បន្នតម្លៃប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យបានថយចុះ ដោយសារគ្រឿងបរិក្ខារសម្រាប់តម្លើង

ដូចជាបន្ទះសូឡាជាពិសេសផលិតផលនាំចូលពីប្រទេសចិនបានថយចុះគួរឱ្យកត់សម្គាល់ក្នុងអំឡុង១០ឆ្នាំក្រោយនេះ។ ឧទាហរណ៍បន្ទះសូឡា ១០០វ៉ាត់ ផលិតផលប្រទេសចិនមានតម្លៃត្រឹមតែ ៦០ដុល្លារនៅភ្នំពេញ បើប្រៀបធៀបតម្លៃប្រហែល១០០ដុល្លារ ក្នុងពេល១០ឆ្នាំមុន។ តម្លៃបន្ទះសូឡានិងឧបករណ៍ដែលផលិតនៅប្រទេសជប៉ុន មានតម្លៃខ្ពស់ជាងផលិតនៅប្រទេសផ្សេង ដោយមានគុណភាពខ្ពស់ជាង។ តម្លៃឧបករណ៍សម្រាប់តម្លើង ដូចជាគ្រឿងបម្លែងចរន្តឆ្លាស់ឬអាំងវែរទ័រ (invertor) និងកុងត្រូល័រ (charge controller) ក៏ប្រែប្រួលថយចុះ ទោះបីមានប្រភេទឧបករណ៍ខ្លះមានផ្លាកសញ្ញាសម្គាល់ផលិតក្លែងក្លាយឬពុំមានគុណភាពច្បាស់លាស់ ដែលធ្វើឱ្យការប្រើប្រាស់ពុំមានប្រសិទ្ធភាព ឬអាចប្រើបានយូរ។

## ២.៤ បញ្ហាប្រឈម និងដំណោះស្រាយក្នុងការប្រើប្រាស់តាមផ្ទះ

ការប្រើប្រាស់ថាមពលអគ្គិសនីជាលក្ខណៈគ្រួសារនៅមានកម្រិត មាននិន្នាការថយចុះ ជាពិសេសនៅពេលដែលបណ្តាញអគ្គិសនីរដ្ឋបានអភិវឌ្ឍរីកដាលនៅទីក្រុងនិងជនបទភាគច្រើន។ថាមពលពន្លឺព្រះអាទិត្យអាចប្រើច្រើនយ៉ាងតាមតម្រូវការថាមពលជាក់ស្តែង អាចចាប់ពី១០០វ៉ាត់ ទៅ១-៥គីឡូវ៉ាត់ ដូចជាប្រើសម្រាប់បូមទឹក ចិញ្ចឹមសត្វពាហណៈ ផ្ទះត្រចៀកកាំ ចិញ្ចឹមត្រី ឬសម្រាប់ឧបករណ៍អគ្គិសនីផ្សេងៗក្នុងផ្ទះដូចជាទូរទស្សន៍ អំពូលភ្លើងជាដើម។ ការអង្កេតរយៈពេលខ្លីនៅភូមិព្រៃគុយ សង្កាត់ព្រៃគុយ ស្រុកកំពង់ស្វាយ ដែលមានចម្ងាយប្រហែល១៥គីឡូម៉ែត្រពីក្រុងស្ទឹងសែនបានទទួលបានពត៌មានអំពីការប្រើប្រាស់និងបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម៖

ក) កង្វះការយល់ដឹងនិងជំនាញច្បាស់ក្នុងចំណោមអ្នកផ្គត់ផ្គង់ និងជាងតម្លើងថាមពលអគ្គិសនីពន្លឺព្រះអាទិត្យ បានធ្វើឱ្យបាត់បង់ទំនុកចិត្តលើការប្រើប្រាស់ក្នុងចំណោមប្រជាជនជនបទ។ មានករណីប្រើអាំងវែរទ័រពីបន្ទះសូឡា២ផ្ទាំងនិងអាគុយ២សម្រាប់បូមទឹក ប៉ុន្តែបានឆេះប្រព័ន្ធបន្ទាប់ប្រើបានមួយ រយៈពេលខ្លីប្រហែលដោយសារកម្លាំងអាំងវែរទ័រមិនគ្រប់តម្រូវការថាមពលម៉ូទ័រ។ ការគណនាតម្រូវការថាមពលនៃឧបករណ៍អគ្គិសនីស្របនឹងថាមពលពន្លឺព្រះអាទិត្យត្រូវអនុវត្តតាមទ្រឹស្តីផងនិងបទពិសោធជាក់ស្តែងថែមទៀត។

ខ) ដោយសារតម្លៃតភ្ជាប់និងតម្លៃបណ្តាញផ្គត់ផ្គង់អគ្គិសនីរបស់រដ្ឋមានតម្លៃថោកនិងងាយស្រួលប្រើ បច្ចុប្បន្នតម្លៃអគ្គិសនីនៅជនបទប្រហែល៦០០រៀលក្នុងមួយគីឡូវ៉ាត់ម៉ោង ដែលធៀបនឹងតម្លៃប្រហែល ២៥០០រៀលនៅ៧-១០ឆ្នាំមុន ធ្វើឱ្យគ្រួសារមួយចំនួនធំបានបោះបង់ការប្រើប្រាស់បន្ទះសូឡា ឬប្រើគ្រាន់តែដើម្បីសាកអាគុយមួយសម្រាប់បំភ្លឺអំពូលសូឡាពេលយប់តែប៉ុណ្ណោះ (រូបភាព២)។



រូបភាព២៖ ការសាកអាគុយដោយផ្ទាល់



រូបភាព៣៖ ការប្រើកុងត្រូល័រនិងអាំងវែរទ័រ

គ)កង្វះការយល់ដឹងការប្រើប្រាស់អាគុយនិងកុងត្រូលល័រក៏ធ្វើឱ្យអាគុយឆាប់ខូចនិងប្រើបាន រយៈពេលខ្លី ដោយសារការប្រើថាមពលអាគុយហួសកំណត់ ដូចជាសម្រាប់បូមទឹក ឬឧបករណ៍ឆ្នាំងភ្លើងដែលស៊ីភ្លើងច្រើន។

ឃ) ការផ្តល់សេវាថែទាំនិងការណែនាំដោយជាងតម្លើងឬក្រុមហ៊ុនផ្គត់ផ្គង់សម្ភារៈសូឡា បន្ទាប់ពីការតម្លើងថាមពលពន្លឺព្រះអាទិត្យ ដែលធ្វើឱ្យដាច់ខូចអាគុយឬផេះអាំងវែរទ័រ។

ង) សម្រាប់តម្រូវការថាមពលលើសពី១គីឡូវ៉ាត់ ការវិនិយោគដើមទី (upfront investment) នៅមានតម្លៃថ្លៃសម្រាប់កសិករដែលមានជីវភាពខ្វះខាត ទោះបីរយៈពេលយូរបន្ទាប់ពី១០ឆ្នាំ វាអាចចំណេញជាងការប្រើប្រាស់ថាមពលផ្សេងទៀត ដែលពិបាកប្រដែងជាមួយបណ្តាញអគ្គិសនីរដ្ឋ។

ច) ពុំទាន់មានការគាំទ្រថវិកាសមស្របឬការលើកទឹកចិត្ត សម្រាប់គ្រួសារដែលចង់ប្រើប្រាស់ ដូចជាការផ្តល់ការប្រាក់ទាប ការលើកលែងពន្ធចំណូល និងការផ្តល់ប្រាក់កម្ចីជាដើម។

ដើម្បីឱ្យមានដំណើរការប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យកម្រិតគ្រួសារមានប្រសិទ្ធភាពនិងបានរីកដាលដល់គ្រួសារជនបទភាគច្រើន គួរមានដំណោះស្រាយខ្លះដូចខាងក្រោម៖

១) ក្រុមហ៊ុនផ្គត់ផ្គង់សម្ភារៈសូឡា និងជាងតម្លើងត្រូវមានការបញ្ជាក់អាជ្ញាបណ្ណច្បាស់លាស់ពីស្ថាប័នជំនាញ ដើម្បីធានាគុណភាពនិងប្រើប្រាស់សមស្របតាមតម្រូវការជាក់ស្តែង។

២) ត្រូវមានការបណ្តុះបណ្តាលវិជ្ជាជីវៈ រយៈពេលខ្លីដែលមានការបញ្ជាក់សញ្ញាបត្របណ្តុះបណ្តាលត្រឹមត្រូវ ដើម្បីធានាការផ្គត់ផ្គង់និងតម្លើងដល់អតិថិជនប្រកបដោយប្រសិទ្ធភាព។

៣)លើកកំពស់ការយល់ដឹងរបៀបប្រើប្រាស់តាមរយៈផ្សព្វផ្សាយផ្ទាំងរូបភាពខិតបណ្ណនិងការសំណេរពន្យល់ខ្លីៗដល់គ្រួសារអតិថិជនដែលចង់ប្រើនិងកំពុងប្រើប្រាស់ប្រព័ន្ធសូឡា។ឧទាហរណ៍រូបភាព៣បង្ហាញពីរបៀបប្រើប្រាស់សមស្រប ដែលអាចប្រើឧបករណ៍អគ្គិសនីទំហំសរុប១៥០វ៉ាត់ ក្នុងរយៈពេល៨ម៉ោងក្នុងពេលយប់បាន (១២វ៉ុលx១៥០+១២វ៉ុលx១០០=៣គីឡូវ៉ាត់ម៉ោង) ដោយរក្សាថាមពលអាគុយឱ្យនៅសល់យ៉ាងហោច៣០%។

៤) ការផ្តល់សេវាគាំទ្រ ទាំងបច្ចេកទេសនិងថវិកា ឥណទានខ្នាតតូច ឬនយោបាយហិរញ្ញវត្ថុសមស្រប (ពន្ធនាំចូល ពន្ធលើសេវាកម្ម និងការលើកទឹកចិត្ត)។

៥) ដោយឡែកសម្រាប់ប្រព័ន្ធតម្លើងសូឡាលើតំបូលរោងចក្រ ឬសហគ្រាសខ្នាតមធ្យម កសិដ្ឋាន នយោបាយទិញលក់ថាមពលដែលប្រើមិនអស់ទៅឱ្យបណ្តាញរដ្ឋក្នុងតម្លៃសមរម្យដើម្បីលើកទឹកចិត្តវិនិយោគឯកជនកាន់តែទូលាយ។

## ៣) សេចក្តីសន្និដ្ឋាន

ការប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យកំពុងមានសក្តានុពល អាចពង្រីកបន្ថែម សម្រាប់ប្រព័ន្ធគ្រប់ប្រើប្រាស់ ទាំងកម្រិតគ្រួសារ ប៉ុន្តែចាំបាច់ឱ្យមានការយល់ដឹងនិងមានជំនាញសមស្រប ក្នុងចំណោមក្រុមហ៊ុនផ្គត់ផ្គង់ ជាងតម្លើង និងគ្រួសារអ្នកប្រើ ជាពិសេសគ្រួសារដែលនៅឆ្ងាយពីបណ្តាញអគ្គិសនីរដ្ឋ។ ថាមពលនេះក៏អាចប្រើបំពេញបន្ថែមឬជំនួសនូវថាមពលផ្សេងទៀតដែលមានតម្លៃថ្លៃជាង ដូចជាថាមពលខ្យល់ឬធ្យូងថ្មឬវារីអគ្គិសនីដែលអាចមានផលប៉ះពាល់ខ្លាំងលើបរិស្ថាននៅពេលអនាគត។ចាំបាច់ឱ្យមានការសិក្សាបន្ថែមទៀតដើម្បីស្វែងយល់អំពីលក្ខខណ្ឌចំណេញ/ខាត និន្នាការតម្លៃនិងទីផ្សារ និងបច្ចេកវិទ្យានិងឧបករណ៍ថ្មីៗ ពាក់ព័ន្ធនឹងការប្រើប្រាស់ប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យ។ នយោបាយហិរញ្ញវត្ថុ ប្រព័ន្ធគាំទ្រនិង ការលើកទឹកចិត្តដល់អ្នកប្រើប្រាស់និងក្រុមហ៊ុនផ្គត់ផ្គង់នឹងជួយការមានកំណើនការប្រើប្រាស់រួមចំណែកកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ ដែលជានយោបាយឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅប្រទេសកម្ពុជា។

រៀបរៀងដោយ នៅ បោនន័រ

## ១- បច្ចេកសព្ទគន្លឹះមិទ្ធិវិទ្យានិងប្រវត្តិវិទ្យា

១-ជនជាតិ/ជាតិពន្ធុ សង្គមមនុស្សមួយក្រុមដែលមានលក្ខណៈសម្គាល់សំខាន់ៗរួមមាន ដូចជា ជាតិសាសន៍ វប្បធម៌ ភាសា ទំនៀមទម្លាប់ ប្រពៃណីជាដើម។ eng. ethnic group

២-ជនជាតិដើម ជាតិពន្ធុដែលរស់នៅលើទឹកដីឬនៅក្នុងប្រទេសណាមួយដំបូងគេតាំងពីដើមរៀងមកហើយមានវប្បធម៌ភាសាទំនៀមទម្លាប់និងប្រពៃណីរបស់ខ្លួនខុសពីជនជាតិដែលជាប្រជាជាតិស្នូល(ឯកសារខ្លះហៅថាជនជាតិដើមភាគតិច)។ eng. indigenous people

៣-ជនជាតិភាគតិច ជាជនជាតិដែលមានចំនួនតិចក្នុងចំណោមប្រជាជនទាំងអស់នៅលើទឹកដីណាមួយ (តំបន់ឬប្រទេស)។ eng. ethnic minority

៤-ប្រជាជន ជនទាំងអស់ដែលកំពុងរស់នៅក្នុងប្រទេសណាមួយ រួមទាំងជនបរទេសអន្តោប្រវេសន៍។ eng. population

៥-ជនបរទេស ជនដែលមកពីប្រទេសណាមួយ ចូលទៅប្រទេសមួយផ្សេងទៀត មានគោលបំណងអ្វីមួយ។ ជនបរទេសមានជនបរទេសអន្តោប្រវេសន៍ ជនបរទេសអនន្តោប្រវេសន៍ និងជនបរទេសអន្តោប្រវេសន៍ជាអ្នកវិនិយោគឯកជន។ eng. foreigner, alien

៦-ប្រជាពលរដ្ឋ ជនទាំងឡាយដែលមានសញ្ជាតិរបស់រដ្ឋដែលខ្លួនកំពុងរស់នៅ។ eng. citizen

៧-ប្រជាជាតិ សហគមន៍មនុស្សដែលត្រូវបានបង្កើតឡើងតាមដំណើរប្រវត្តិសាស្ត្រ មានលក្ខណៈសម្គាល់រួមគ្នា ដូចជា ភាសា ទំនៀមទម្លាប់ ប្រពៃណី និងពូជសាសន៍ ព្រមទាំងមានមនសិការនិងផលប្រយោជន៍ដោយឡែក។ ប្រជាជាតិខ្លះពុំមានរដ្ឋទេ(មានទឹកដីនិងប្រជាជន តែពុំមានអង្គការនយោបាយសម្រាប់ធានាអធិបតេយ្យភាពពេញលេញ) ខណៈរដ្ឋសហព័ន្ធខ្លះមានប្រជាជាតិច្រើន(អតីតរដ្ឋសហព័ន្ធយូហ្គោស្លាវីមុនឆ្នាំ១៩៩១មានប្រជាជាតិជាផ្លូវការចំនួន៦)។ eng. nation

៨-ប្រទេស ទឹកដីនៃប្រជាជាតិមួយដែលកំណត់ដោយព្រំដែននៅក្នុងទីតាំងភូមិសាស្ត្រមួយ។ប្រទេសមួយអាចជារដ្ឋដែលមានឯករាជ្យ និងអធិបតេយ្យ ឬអាចជារដ្ឋគ្មានឯករាជ្យ និងអធិបតេយ្យ។ eng. country

៩-រដ្ឋ សហគមន៍នយោបាយដែលមានការចាត់តាំងនៅក្រោមប្រព័ន្ធរដ្ឋាភិបាលមួយ(នីតិប្បញ្ញត្តិ នីតិប្រតិបត្តិ និងតុលាការ)។ រដ្ឋមានលក្ខណៈសម្គាល់៤យ៉ាង គឺទឹកដី ប្រជាជន រដ្ឋាភិបាល និងសមត្ថភាពគតិយុត្តក្នុងទំនាក់ទំនងជាមួយរដ្ឋផ្សេងទៀត។ ប៉ុន្តែនៅក្នុងប្រទេសដូចជាសហរដ្ឋអាមេរិក អូស្ត្រាលី ប្រេស៊ីល... រដ្ឋក៏សំដៅដល់អង្គភាពនយោបាយដែរ ប៉ុន្តែមិនមានអធិបតេយ្យទេ គឺស្ថិតនៅក្រោមអំណាចកណ្តាលមួយ ហៅថារដ្ឋសហព័ន្ធ។ eng. state

១០-រដ្ឋប្រជាជាតិ ទម្រង់មួយនៃអង្គការនយោបាយដែលក្នុងនោះសហគមន៍មនុស្សដែលមានប្រវត្តិសាស្ត្រ ប្រពៃណីទំនៀមទម្លាប់ភាសានិងពូជសាសន៍ដូចគ្នារស់នៅក្រោមរដ្ឋាភិបាលមួយពោល គឺការត្រួតគ្នារវាងរដ្ឋដែលជាអង្គការនយោបាយនិងប្រជាជាតិដែលផ្តោតលើអត្តសញ្ញាណនៃសហគមន៍មនុស្ស។ eng. nation-state

១១-រដ្ឋពហុជាតិ រដ្ឋអធិបតេយ្យមួយដែលមានប្រជាជាតិពីរឬច្រើននៅក្នុងនោះ ខុសពីរដ្ឋប្រជាជាតិដែលមានតែប្រជាជាតិមួយ។រដ្ឋពហុជាតិក៏អាចជារដ្ឋដែលមានពហុវប្បធម៌ពហុភាសានិង/ឬពហុពូជសាសន៍ ដូចជាសហរដ្ឋអាមេរិក រុស្ស៊ី ឥណ្ឌា ចិនជាដើម។ eng. multinational state

១២-រដ្ឋសហព័ន្ធ ដែនដីនៃសហគមន៍ប្រជាជាតិមួយដែលប្រព័ន្ធគ្រប់គ្រងមានពីរកម្រិតគឺមានការបែងចែកអំណាចរវាងរដ្ឋាភិបាលសហព័ន្ធនិងរដ្ឋាភិបាលនៃរដ្ឋសមាជិក។រដ្ឋាភិបាលទាំងពីរកម្រិតមានការបែងចែកសមត្ថកិច្ចខុសគ្នាដែលក្នុងនោះរដ្ឋាភិបាលសហព័ន្ធមានសមត្ថកិច្ចផ្តាច់មុខសំខាន់ៗយ៉ាងតិចបួន គឺវិស័យការពារជាតិ វិស័យការបរទេស វិស័យបោះពុម្ពក្រដាសប្រាក់ និងវិស័យពាណិជ្ជកម្មអន្តរជាតិ ឧ.ប្រទេសកាណាដា សហរដ្ឋអាមេរិក ឥណ្ឌា។ eng. federal state

១៣-ឯកត្តរដ្ឋ រដ្ឋគ្រប់គ្រងដោយអំណាចកណ្តាល ដែលមានរបបនយោបាយនិងគតិយុត្តតែមួយ។ eng. unitary state

១៤-រដ្ឋអធិបតេយ្យ រដ្ឋដែលមានប្រជាជាតិរស់នៅជាអចិន្ត្រៃយ៍មានទឹកដីមួយជាកំណត់មានរដ្ឋាភិបាលដែលមិនស្ថិតនៅក្រោមអំណាចនៃរដ្ឋផ្សេងទៀតនិងមានសមត្ថភាពគតិយុត្តទាក់ទងជាមួយរដ្ឋដទៃទៀត។ eng. sovereign state

ដោយ បណ្ឌិតសភាចារ្យ ឆយ អូន

**គំនិតគួរចងចាំ**

« មនុស្សចេះសម្អាតខាងក្រៅខ្លួន ចិត្តខាងក្នុងក៏ស្អាតដែរ
បើបែរជាក្រខ្វក់ខាងក្រៅហើយ ចិត្តខាងក្នុងពិតជាក្រខ្វក់។ »

សម្តេចព្រះធម្មលិខិត ល្វី ឯម វជិរប្បញ្ញោ

## ២- ស្វែងយល់អំពីប្រពៃណីកាន់បិណ្ឌនិងភ្ជុំបិណ្ឌ

ប្រជាពលរដ្ឋខ្មែរបានប្រតិបត្តិប្រពៃណីកាន់បិណ្ឌនិងភ្ជុំបិណ្ឌ ក្នុងគោលបំណងធ្វើបុណ្យឧទ្ទិសកុសលដល់ជនជាតិខ្មែរ ដែលបានភ្លាត់គតិទៅកើតជាសត្វនរក ប្រេត ឱ្យរួចរំដោះចាកផុតពីសត្វនរក ប្រេតប៉ុណ្ណោះ ព្រោះគេជឿថា សត្វនរក ប្រេតទាំងអស់នោះ ទទួលតែទុក្ខ គ្មានអ្វីស៊ីទេ ស៊ីតែខ្ទុះនិងឈាម។ ប្រពៃណីកាន់បិណ្ឌនិងភ្ជុំបិណ្ឌនេះ បានទទួលឥទ្ធិពលពីលទ្ធិព្រះពុទ្ធសាសនា។ ប្រសិនបើពិនិត្យទៅលើទ្រឹស្តីពុទ្ធនិយម យើងឃើញថាមនុស្សស្លាប់តែរូបកាយទេ តែព្រលឹងពុំស្លាប់ឡើយ តែងអន្ទោលទៅចាប់កំណើតនៅភពផ្សេងៗ តាមផលកម្មរបស់ខ្លួន។ អ្នកប្រព្រឹត្តបាបកម្ម តែងទៅកើតជាប្រេតដែលទទួលរងទុក្ខវេទនាតាមអាយុកម្ម។

ផ្នត់គំនិតរបស់ខ្មែរ ចាប់ពីថ្ងៃ១រោចខែអាសាធ ជាថ្ងៃព្រះសង្ឃចូលវស្សា ដល់ថ្ងៃ១៥កើតខែអស្សុជ ជាថ្ងៃព្រះសង្ឃចេញព្រះវស្សា ខ្មែរចាប់មានគំនិតធ្វើបុណ្យឧទ្ទិសកុសលជូនដល់វិញ្ញាណក្ខន្ធបុព្វបុរសរបស់ខ្លួន មានមាតាបិតាជីដូនជីតា ញាតិកាទាំង៧សន្តានជាដើម។

ក- អ្វីទៅហៅថា កាន់បិណ្ឌ ឬដាក់បិណ្ឌ?

ទម្លាប់របស់ខ្មែរយើង កាលបើគេនឹកឃើញដល់គុណមាតាបិតា ឬញាតិកាណាមួយ គេតែងធ្វើចង្ហាន់យកទៅប្រគេនព្រះសង្ឃ ដើម្បីឧទ្ទិសកុសលជូនដល់អ្នកទាំងនោះ។ ប៉ុន្តែការបំពេញកុសលតាមបំណងរបស់ខ្លួនឃើញថាមានថ្ងៃខ្លះមានពុទ្ធបរិស័ទច្រើនលើសលប់មានចង្ហាន់បរិបូរហូរហៀរហូតដល់ព្រះសង្ឃឆាន់មិនអស់ ហើយនៅថ្ងៃខ្លះទៀតមានពុទ្ធបរិស័ទតិច ឬជួនកាលគ្មានតែម្តង ធ្វើឲ្យព្រះសង្ឃមានចង្ហាន់ឆាន់មិនគ្រប់គ្រាន់ ឬគ្មានចង្ហាន់ឆាន់សោះ។

ដោយមានមូលហេតុដូចខាងលើនេះហើយទើបធ្វើឲ្យពុទ្ធបរិស័ទធ្វើចង្ហាន់ទៅប្រគេនព្រះសង្ឃតាមក្រុមតាមការសន្មតគ្នារៀងរហូតមកដល់សព្វថ្ងៃដែលយើងហៅថាដាក់វេនឬតាមវេន។ប៉ុន្តែនៅខាងដើមនៃថ្ងៃចូលព្រះវស្សា ប្រជាពុទ្ធបរិស័ទជាប់រវល់មមាញឹកដកស្ទូងស្រូវស្រែ មិនអាចរៀបចំចង្ហាន់ទៅប្រគេនព្រះសង្ឃតាមវេន ឱ្យគ្រប់៣ខែបាន។ លុះដល់ថ្ងៃ១រោចទៅទល់នឹងថ្ងៃ១៥រោចខែភទ្របទ ទើបបានសន្មតគ្នារៀបចង្ហាន់ទៅប្រគេនព្រះសង្ឃតាមវេន ដែលគេហៅថា «ដាក់បិណ្ឌ» ជារៀងរាល់ឆ្នាំ។ នៅខាងដើមនៃថ្ងៃដាក់បិណ្ឌ និងខាងចុងនៃថ្ងៃកាន់បិណ្ឌ ឬថ្ងៃបិណ្ឌ ដែលមិនមែនជាវេនរបស់ខ្លួន ទុកជាថ្ងៃធ្វើបុណ្យតាមសទ្ធារៀងៗខ្លួន។

ខ- ភ្ជុំបិណ្ឌ :

ពាក្យថា «ភ្ជុំបិណ្ឌ» គឺគេប្រមូលវេន ឬក្រុមមនុស្សអ្នកកាន់បិណ្ឌ ឬដាក់បិណ្ឌចំនួន១៤វេន ឬ១៤ក្រុមនោះ មកធ្វើរួមគ្នាតែមួយថ្ងៃ ដែលគេហៅថាថ្ងៃ ភ្ជុំបិណ្ឌ។

ខ១- ពិធីកាន់បិណ្ឌ និងភ្ជុំបិណ្ឌក្នុងព្រះបរមរាជវាំង : ព្រះមហាក្សត្រព្រមទាំងព្រះរាជវង្សានុវង្សទ្រង់ប្រារព្ធធ្វើពីធីកាន់បិណ្ឌ និងភ្ជុំបិណ្ឌ មានចំនួនតែ៥ថ្ងៃទេ គឺចាប់ពីល្ងាចនៃថ្ងៃ១១រោច ១២រោច ១៣រោច ១៤រោច ជាថ្ងៃដាក់បិណ្ឌ។ រីឯថ្ងៃ១៥រោចខែភទ្របទ ជាថ្ងៃភ្ជុំបិណ្ឌ។ (សូមអានសៀវភៅព្រះរាជពិធីទ្វាទសមាស : ឧកញ៉ា ចាប ពិន ទំព័រ៤៥...)។

២២- ពិធីកាន់បិណ្ឌ និងភ្ជុំបិណ្ឌក្នុងស្រទាប់ប្រជានុរាស្ត្រ :

-គ្រឿងសក្ការបូជា:សម្រាប់ថ្វាយព្រះរតនត្រ័យ និងពពួកទេវតាទាំងអស់ដែលមករង់ចាំទទួលបុញ្ញកម្ម ដែលយើងឧទ្ទិសជូនទៅនោះ ហើយពពួកទេវតាទាំងនោះបាននាំយកបុញ្ញកម្មទាំងនោះ ទៅប្រាប់ថាអ្នកនេះ ឈ្មោះនេះនៅស្រុកនេះបានឧទ្ទិសផលមកជូនសូមឲ្យអ្នកទទួលយកនឹងបានរួចរំដោះចាកទុក្ខវេទនាផងទាំងពួង។ ឯគ្រឿងសក្ការបូជាទាំងនោះមាន ៖ ទៀន៥ ធូប៥ ស្លាធម៌កូនចេក១គូ បាយសីប៉ាក់ឆាម១គូ...។

- ផ្កាបិណ្ឌ : ធ្វើពីឈើ មានកម្ពស់១ហត្ថ១ចំអាម មានសំណុំផ្កាធំក្រោមតូចលើ មានបង្គោលឈើមូល១ ទំហំខាងគល់ប៉ុនមេដៃ ខាងចុងប៉ុនកូនដៃ គេយកក្ដារកម្រាស់ម្រាមដៃធ្វើជាកង់មូល ចោះរន្ធនៅចំកណ្ដាល សម្រាប់ស៊កបង្គោល នៅខាងក្រោមធំខាងលើតូច តាមលំដាប់ទាំង៥ថ្នាក់។ ក្ដារថ្នាក់ក្រោមមានទំហំ៥ធ្នាប់ ឯក្ដារថ្នាក់លើបន្ថយបន្ទាប់ មានរាងតូចរៀវរហូតដល់ថ្នាក់លើតាមលំដាប់។ ប្រដាប់ផ្កាបិណ្ឌនេះ រចនាដោយក្បាច់ស្ពាន់ក្រាប់ពណ៌ផ្សេងៗ ជាក្បាច់កញ្ចាំងបិទភ្ជាប់ជុំវិញកង់ទាំង៥ថ្នាក់ មានក្បាច់ដកចន្ទន៍បិទភ្ជាប់៥ជុំក្នុងមួយថ្នាក់។ នៅខាងក្រោយក្បាច់ដកចន្ទន៍ គ្រប់ថ្នាក់គ្រប់កន្លែងមានដែករស់ធ្វើជាដងដោតផ្កាញ័រ ដែលធ្វើពីស្ពាន់ក្រាប់ឱ្យខ្ពស់ជាងក្បាច់ដកចន្ទន៍បន្តិចឡើង។នៅខាងក្រោយក្បាច់ដកចន្ទន៍ទាំង៥នៃថ្នាក់១ ខាងក្រោមបង្អស់ គេយកចម្រៀកឫស្សីតូចៗប៉ុនទ្រនង់ស្លឹកដូងធ្វើជាដង ដោតទង់ក្រពើ៥ ដែលធ្វើពីស្ពាន់ក្រាប់។ នៅខាងចុងដងទង់នោះមានដោតផ្កាស្ពាន់ក្រាប់ដែរ។ គេបន្ថែមថ្នាក់តូចមួយនៅខាងក្រោមទៀត ដោតភ្ជាប់ស្ពាន់ក្រាប់ជារូបនាគ៤ យកក្បាលនាគនីមួយៗទៅភ្ជាប់ពីខាងក្រោមក្បាច់ដកចន្ទន៍ថ្នាក់ក្រោមបំផុត។ យកកន្ទុយនាគទៅភ្ជាប់នឹងគល់បង្គោលខាងក្រោម។ ក្នុងមាត់នាគទាំង៤នោះមានក្បាច់ស្លឹកពោធិ៍សំយុងចុះ ធ្វើជានាគទ្រផ្កាបិណ្ឌ។តាមវចនានុក្រមខ្មែរ សម្ដេចព្រះសង្ឃរាជ ជួន ណាត ទ្រង់បានពន្យល់ពាក្យ «ផ្កាបិណ្ឌ» នេះថា ជាគ្រឿងលម្អដែលរចនាដោយស្ពាន់ក្រាប់មានដងដោតបានសម្រាប់សម្គាល់ក្នុងពិធីធ្វើបុណ្យកាន់បិណ្ឌ។គេយកផ្កាបិណ្ឌទាំងអស់ទៅដាក់លើតោក ដោយតោក១ដាក់ផ្កាបិណ្ឌ១។ តោកដាក់ផ្កាបិណ្ឌទាំងអស់ គេត្រូវរៀបជាពីរជួរ គឺជួរមុខនិងជួរក្រោយ។ តោកនៅជួរមុខ គេដាក់កែវ តូចៗចំនួន៥ សម្រាប់ដាក់បង្អែមនិងចម្អាបនៅក្នុងតោកនីមួយៗ។ គេពូតបាយលុញឱ្យមូលជាដុំៗ យកទៅដាក់ក្នុងតោក ឱ្យបានគ្រប់តោកដែលមាន។ បាយទាំងនេះគេយកអង្ករដំណើបសុទ្ធល្អមកដាំចំហុយឲ្យឆ្អិនស្អិតរមួតដោយដាក់ខ្ទិះដូងលូសណ្ដែកបាយ...ហើយទើបគេយកមកពូតជាពំនូត លុញឱ្យមូលល្អ ដែលតាមទំនៀមរាស្ត្រហៅថា «បាយដើងបិណ្ឌ»។

វចនានុក្រមខ្មែរដដែលនៅបានឱ្យនិយមន័យពាក្យថា « បិណ្ឌ » គឺការប្រមូលឱ្យមូល ឬការពូតឱ្យទៅជាដុំៗ ។ ប្រសិនបើយើងប្រើពាក្យនេះជាឈ្មោះនៃពិធីធ្វើទានម្យ៉ាង(តាមប្រពៃណីរបស់ប្រទេស)ធ្វើបានពីត្រឹមថ្ងៃ១រោចដល់១៥រោចខែភទ្របទ (១៥ថ្ងៃ)។ នៅពេលនិមន្តព្រះសង្ឃសូត្រធម៌ «បរាភវសូត្រ» នៅថ្ងៃទី១ គេដាក់១ដុំ ថ្ងៃទី២ គេដាក់២ដុំ... ដល់ ថ្ងៃ១៥រោច គេដាក់១៥ដុំ។ លុះដល់ថ្ងៃចប់ភ្ជុំបិណ្ឌ គេយកបាយដើង បិណ្ឌនេះ ទៅព្រាចតាមស្រែចំការរបស់ខ្លួន ក្នុងគោលបំណងឱ្យដីស្រែចម្ការមានជីវជាតិល្អ បានផលផ្កាផ្លែល្អ ច្រើន។

- ជើងទ្រផ្កាបិណ្ឌ : គឺជាឈើរាងមូល ឬ៤ជ្រុង ទំហំ៨ធ្នាប់ រាងធំក្រោមតូចលើ កំពស់៥ធ្នាប់ សម្រាប់ធ្វើជាជើងទ្ររាងផ្កាបិណ្ឌ ដើម្បីឲ្យមានជំហរឈរត្រង់ទៅលើ។

-បាយបត្តបូរ:ជាបាយបំពេញបាត្រ(បាយរាប់បាត្រ)ឬបាយសម្រាប់បំពេញបាត្រគឺបាយដែលទាយកគេទុកបម្រុងនឹងថែម ក្រែងព្រះសង្ឃខ្វះខាតឆាន់មិនគ្រាន់។

-បាយបិតបូរ:ជាបាយសម្រាប់បំពេញផលឲ្យប្រេត បានសេចក្តីថា បាយដែលទាយកប្រគេនភិក្ខុសង្ឃ ហើយឧទ្ទិសផលបុណ្យជូនទៅបុគ្គល ដែលចែកឋានទៅកាន់បរលោកហើយ។

- បាយបិណ្ឌ : ជាបាយដែលធ្វើឡើងដោយពំនូតបាយដំណើប ចម្អិនជាមួយខ្ទិះដូងលាយជាមួយសណ្តែកបាយ សណ្តែកដី ល្ង... ទៅតាមការនិយមរបស់ស្រុកនីមួយៗ។ គេដាក់បាយបិណ្ឌក្នុងថាសមួយយកទៅវត្ត នៅកណ្តាលបាយបិណ្ឌមានបាយបិតបូរដែលគេដាក់លើជើងពានតូចមួយ ធ្វើមានរាងដូចសាជី ហើយគ្របស្លឹកពីលើ ដោយចោះកំពូលទុកដោតទៀនធូបនិងផ្កា។ បច្ចុប្បន្ន ពុទ្ធបរិស័ទខ្មែរដោយសារពេលវេលាចង្អៀត និងមានបញ្ហាចោទក្នុងជីវភាព បាយបិណ្ឌគេហាក់ពុំសូវធ្វើតាមរបៀបខាងលើនេះទេ។ គេយកបាយសម្លធម្មតាដួសដាក់ចានស្រាក់យកទៅវត្ត ដើម្បីរាប់បាត្រជំនួសបាយបិណ្ឌ។

២៣- ប្រវត្តិបុណ្យកាន់បិណ្ឌនិងភ្ជុំបិណ្ឌ :

ប្រជារាស្ត្រខ្មែរបានឱ្យតម្លៃ និងសារៈសំខាន់ទៅលើបុណ្យធំៗពីរ គឺបុណ្យកាន់បិណ្ឌ-ភ្ជុំបិណ្ឌ និងបុណ្យចូលឆ្នាំថ្មី។ គេតែងនាំគ្នាទៅធ្វើបុណ្យកាន់បិណ្ឌ-ភ្ជុំបិណ្ឌ ក្នុងទីអារាមដែលត្រូវប្រព្រឹត្តទៅ តាមកាលវេលាកំណត់១៥ថ្ងៃ ចាប់ពីថ្ងៃ១រោចដល់ថ្ងៃ១៥រោចខែភទ្របទ។ ក្នុងអំឡុងពេលនេះ គេតាំងចិត្តដាច់ខាតត្រូវតែទៅវត្តឱ្យបានម្តងយ៉ាងតិច ក្នុងថ្ងៃណាមួយមិនអាចខកខានបានឡើយ ទោះជាមានការមមាញឹក ឬក្រីក្រលំបាកយ៉ាងណាក៏ដោយ ជាពិសេសនៅថ្ងៃ១៥រោចដែលជាថ្ងៃបង្ហើយគេហៅថា«ភ្ជុំបិណ្ឌ»។រឿងហេតុទាំងអស់នោះកើតមានឡើងក៏ដោយសារគេមានជំនឿយ៉ាងមុតមាំតាមចាស់ទុំពន្យល់ណែនាំនិងប្រតិបត្តិជារៀងរាល់ឆ្នាំតៗគ្នាមក។ ផ្តត់ជំនឿខ្មែរដែលនឹកគិត និងអាលោះអាល័យចំពោះញាតិមិត្ត ដែលបានចែកឋានទៅហើយ មានមាតាបិតា ជីដូនជីតា បងប្អូន កូនចៅ តែកាលណាដល់វេរ អាចមកទទួលយកភាគផលអានិសង្សបិណ្ឌ។ ពីព្រោះអ្នកដែលចែកឋានទៅនោះ ខ្លះមានបាបកម្មត្រូវទៅសោយទុក្ខទោសនៅឋាននរក ប្រេត កើតក្នុងអបាយភូមិលំបាកវេទនាខ្លាំងណាស់។ ឋាននោះស្ថិតនៅជ្រៅឆ្ងាយពីឋានមនុស្ស មិនអាចងើបមកបានឃើញពន្លឺព្រះអាទិត្យទេ គ្មានសម្លៀកបំពាក់ គ្មានអាហារបរិភោគឡើយ។ លុះដល់វេរបុណ្យកាន់បិណ្ឌ-ភ្ជុំបិណ្ឌ ទើបគេដោះលែងឱ្យមកទទួលយកផលល្អានិសង្ស ដែលញាតិសារលោហិតធ្វើបុណ្យឧទ្ទិសជូន។ ម្យ៉ាងទៀត គេខ្លាចអ្នកទាំងអស់នោះដាក់ប្រទេចបណ្តាសារឱ្យគេហិនហោច ប្រសិនបើដើរស្វែងរកគ្រប់៧វត្ត ហើយមិនឃើញសាច់ញាតិធ្វើបុណ្យឱ្យទេ។ជាមួយគ្នានេះដែរគេមានក្តីសង្ឃឹមមួយទៀតថាអំពើកុសលដែលគេមានសទ្ធាបានបរិច្ចាគឧទ្ទិសទៅនោះ នឹងងាកបែរមកឱ្យសព្វសាធុការពរ ហើយគេនឹងត្រូវបានទទួលវិញដែរ នូវសេចក្តី សុខ និងសេចក្តីចម្រើន។ ដើមកំណើតបុណ្យនេះ មិនមានឯកសារណាមួយបានបរិយាយថា បានចាប់ធ្វើពី សម័យណាទេ ប៉ុន្តែក្នុងគម្ពីរតិរោកុឌ្ឌសូត្របានបរិយាយថា ៖ ព្រះបាទពិម្ពិសារមានពួកញាតិមួយក្រុមបានបំពេញទានមិនបរិសុទ្ធ គឺស៊ីបាយមុនលោក លុះលាចាកលោកទៅកាន់លោកខាងមុខក៏កើតជាប្រេត។ លុះ ដល់ព្រះពុទ្ធព្រះនាម កុក្កុសន្ធោ បានត្រាស់ដឹងឡើងក្នុងលោក ពួកប្រេតទាំងនោះទៅសួរព្រះអង្គថា « ចុះយើង ខ្ញុំកាលណាបានអាហារបរិភោគ ?»។ព្រះពុទ្ធត្រាស់ថា«ចាំសួរព្រះពុទ្ធជាន់ក្រោយចុះក្នុងសាសនាគតថាគតអ្នកទាំងឡាយ

មិនត្រូវបានអាហារបរិភោគទេ »។ លុះមកដល់ព្រះពុទ្ធព្រះនាម នាគមនោ បានត្រាស់ដឹង ក៏ត្រាស់ប្រាប់ដូចព្រះពុទ្ធមុនទៀត។ ពេលព្រះពុទ្ធព្រះនាម កស្សបោ បានត្រាស់ដឹង ក៏មានហេតុការណ៍ដូចគ្នានេះដែរ។ ទើបមកដល់ព្រះពុទ្ធព្រះនាមសមណគោត្តមយើងនេះបានត្រាស់ដឹងព្រះអង្គទ្រង់ត្រាស់បន្ទូលថា«ចាំមើលព្រះបាទពិម្ពិសារ ដែលជាញាតិរបស់អ្នកទាំងឡាយ ទ្រង់ឲ្យទានដល់ តថាគត នោះនឹងញុំាងអាហារឱ្យសម្រេចដល់អ្នកទាំងឡាយ»។លុះព្រះបាទពិម្ពិសារបានថ្វាយទានជាដំបូងហើយមិនផ្សាយទៅឱ្យពួកញាតិក៏ស្រាប់តែពួកប្រេតជាញាតិទាំងឡាយនោះ យំស្រែកទ្រហឹងក្នុងពេលរាត្រីនោះ។ ព្រះ បាទពិម្ពិសារស្ដេចយាងទៅកាន់វត្តវេឡុវ័នហើយទូលសួរព្រះពុទ្ធ ព្រះអង្គត្រាស់ថា « ពួកប្រេតជាញាតិរបស់ព្រះអង្គ នាំគ្នាយំទារអាហារ ព្រោះពួកប្រេតទាំងនោះត្រូវបានអាហារបរិភោគក្នុងសាសនាតថាគតប៉ុន្តែព្រះអង្គបានធ្វើបុណ្យហើយមិនបានផ្សាយផលទៅឱ្យ។ព្រះបាទពិម្ពិសារទ្រង់បានជ្រាបហើយក៏ចាត់ចែងធ្វើបុណ្យបញ្ជូនទៅឲ្យ។ពួកប្រេតទាំងនោះក៏បានទទួលផលក្នុងពេលនោះ ហើយក៏បានទៅកើតក្នុងទិព្វវិមាន ដោយសុខរៀងដរាបទៅ។

ខ៤- តើប្រេតជាអ្វី?

តាមវចនានុក្រមខ្មែរ  ប្រេតជាពាក្យសំស្រ្កឹត បើបាលីហៅថា បេត សំដៅដល់សត្វកើតក្នុងអបាយភូមិពួកមួយ : ពួកប្រេត ។ គុ. អ្នកដែលធ្វើមរណកាលទៅកាន់បរលោកហើយ។ អបាយភូមិ ជាន់ឬឋានអបាយកំណើតសត្វដែលប្រាសចាកសេចក្ដីចម្រើន មានពួកនរក តិរច្ឆាន ប្រេត អសុរកាយ ទាំងបួននេះជាអបាយភូមិ។ ប្រេត គឺជាសត្វដែលបានកើតក្នុងអបាយភូមិ ជាក្រុមសត្វនរក អសុរកាយ ដែលជាសត្វមានបាបច្រើនរងទុក្ខវេទនាស៊ីតែវត្ថុមិនស្អាតជាវត្ថុលាយដោយខ្ទុះនិងឈាម។ពួកប្រេតខ្លាចពន្លឺណាស់ហើយដើររកស៊ីតាមសំយាបផ្ទះញាតិ...។ តាមគម្ពីរមិលិន្ទប្បញ្ហាសម្ដែងថា ប្រេតមានបួនយ៉ាង ៖

- ប្រេតដែលចិញ្ចឹមជីវិតដោយខ្ទុះនិងឈាម
- ប្រេតដែលស្រេកឃ្លានអាហារជានិច្ច
- ប្រេតដែលភ្លើងឆេះជានិច្ច
-ប្រេតដែលភ្លើងឆេះជានិច្ច
-ប្រេតដែលចិញ្ចឹមជីវិតដោយផលដែលបុគ្គលដទៃឧទ្ទិសទៅឱ្យ។

គ- កម្មវិធីបុណ្យ :

ពេលរសៀលថ្ងៃ១៥កើតខែភទ្របទ ពុទ្ធបរិស័ទបានមកជួបជុំគ្នានៅសាលាឆាន់។ អ្នកដែលបានព្រមទទួលបន្ទុកចំណាយប្រាក់កាសក្នុងការទិញម្ហូបអាហារភេសជ្ជៈឬរណ្ដាប់រៀបចំពិធីសម្រាប់ថ្ងៃទី១គឺថ្ងៃ១រោចខែភទ្របទ ដែលគេនិយមហៅថាកាន់បិណ្ឌ ហើយនិយាយថាបិណ្ឌ១ គេត្រូវមកកាន់ទីវត្ត ដើម្បីដំណើរការដូចតទៅ ៖

គ១-អ្នកកាន់វេននិងពុទ្ធបរិស័ទទាំងអស់នាំគ្នារៀបចំបាយបិណ្ឌជាមួយគ្នានោះដែរគេរៀបចំជើងបិណ្ឌជាពីរចំណែក ទុកប្រគេនព្រះសង្ឃមួយចំណែក សម្រាប់ឧទ្ទិសដល់អ្នកដែលចែកឋានទៅ និងជូនអាចារ្យមួយចំណែកនៅថ្ងៃកាន់បិណ្ឌរបស់គេដើម្បីជាការដឹងគុណដែលលោកហត់នឿយជួយចាត់ចែងពិធី។ការរៀបជើងបិណ្ឌមានដាក់ផ្លែឈើគ្រប់មុខ នំ អង្ករ ប្រាក់កាសខ្លះតាមសទ្ធា និងចំណូលចិត្តរបស់អ្នកកាន់បិណ្ឌ ឬអ្នកដទៃ

ផ្សេងទៀតដែលគេបានយកមកដាក់ចូលរួមជាមួយដែរ។ គេពូតបាយធ្វើជាផ្កាបិណ្ឌ កំណត់រាប់តាមចំនួនវេនបិណ្ឌ។ ឧបមាថាថ្ងៃបិណ្ឌ៥ គេធ្វើ៥ ថ្ងៃបិណ្ឌ១០ គេធ្វើ១០ដែរ ហើយផ្កាបិណ្ឌនេះ មានដោតទង់តូចៗ និងផ្កាចំរុះពណ៌លម្អពីលើកំពូលសាជី សម្រាប់ឧទ្ទិសថ្វាយដល់ព្រះចូឡាមណីចេតីយ។

គ២- នៅពេលព្រលប់លោកអាចារ្យអ្នកកាន់វេននិងពុទ្ធបរិស័ទទាំងអស់ប្រារព្ធធ្វើពិធីថ្វាយបង្គំព្រះនិងឧទ្ទិសហៅដួងព្រលឹងអ្នកដែលចែកឋានទៅ អញ្ជើញមកទទួលកុសល និងសូត្រប្រតិដ្ឋានបាយបិណ្ឌ។

គ៣- ព្រះសង្ឃនិមន្តចូលក្នុងសាលាឆាន់ ដើម្បីសូត្រធម៌ចម្រើនព្រះបរិត និងឧទ្ទិសកុសលបាចទឹកមន្តគឺពិធីក្រុងពាលីបាយបិណ្ឌ។

គ៤- ព្រះសង្ឃទេសនា ភាគច្រើនទេសពីអានិសង្សនៃកុសល ដែលបានឧទ្ទិសដល់អ្នកចែកឋាន ឬពីកុសលផ្សេងៗ ដែលពាក់ព័ន្ធដល់ពិធីកាន់បិណ្ឌ-ភ្ជុំបិណ្ឌ។

គ៥- ព្រះប្រធានសង្ឃ ប្រទានឱវាទខ្លះៗសម្រាប់កម្មវិធីបុណ្យនាវេលាទៀបភ្លឺ។

ថ្ងៃស្អែក ពេលជិតភ្លឺវេលាប្រហែលម៉ោង៤ ព្រះសង្ឃទូងស្គរជាសញ្ញាដាស់ឲ្យភ្ញាក់ពីដំណេក ដើម្បីដំណើរការបន្តដូចខាងក្រោម ៖

-ព្រះសង្ឃចូលក្នុងព្រះវិហារសូត្រធម៌ថ្វាយបង្គំ។ រីឯពុទ្ធបរិស័ទ និងអ្នកកាន់វេននាំគ្នាចូលទៅសាលាឆាន់ អុជទៀនធូប រៀបចំបាយបិណ្ឌ និងថ្វាយបង្គំព្រះ។

-ព្រះសង្ឃនិមន្តចេញពីព្រះវិហារ ចូលមកកាន់សាលាឆាន់ ដើម្បីសូត្រ បរាភវសូត្រ ដែលគេនិយមហៅកាត់ថា « សូត្របរា »។ បរាភវសូត្រនេះគឺជាធម៌ដែលចែងពីក្តីវិនាស១២ប្រការ មានអំពើផិតក្បត់ ការលេងល្បែង ស្រី ស្រា ការមិនត្រេកអរក្នុងធម៌ អ្នកមានទ្រព្យមិនចិញ្ចឹមមាតាបិតា ការសេពគប់ បុគ្គលពាល...។

-សូត្របរាចប់ ព្រះសង្ឃបង្សុកូល និងឧទ្ទិសបាយបិណ្ឌដល់ប្រេតនរក។ ក្រោយពេលព្រះសង្ឃសូត្រចប់ អាចារ្យវាយគងហើយភ្លេងពិណពាទ្យចាប់កំដរពិធី។

ភ្លេងប្រគំកំដរជាហូរហែ ព្រមគ្នាជាមួយព្រះសង្ឃសូត្រធម៌ឧទ្ទិសជាបន្តបន្ទាប់នោះ ពួកពុទ្ធបរិស័ទទាំងអស់កាន់ចានបាយបិណ្ឌរៀងៗខ្លួន ដើរតម្រង់ទៅព្រះវិហារ ដើម្បីប្រទក្សិណ៣ជុំព្រះវិហារ ដែលគេហៅថា « បោះបាយបិណ្ឌ »។ ពេលដើរជុំវិញព្រះវិហារនោះ គេត្រូវដុតធូបប្រាំសរសៃនៅលើចានបាយបិណ្ឌ។ ឱកាសដើរប្រទក្សិណបានមួយជុំ អាចារ្យស្រែកប្រកាសថា « អនុមោទនា លោកអើយ! ទាំងអស់គ្នាស្រែកទទួលថា « សាធុ! » រួចគេចាប់យកបាយមួយដុំដាក់ទៅលើដី ឬគ្រវែងទៅកាន់ទីឆ្ងាយ ហើយដោតធូបមួយសរសៃ ដោតផ្កាឈូក ឬផ្កាផ្សេងៗមួយទងនៅលើដីដែរ។ គេធ្វើបែបនេះគម្រប់បីដង។ រីឯបាយបិណ្ឌនិងធូបនៅសល់ គេនាំយកតាមអាចារ្យដែលអញ្ជើញចេញទៅក្រៅវត្ត ទៅកាន់ទីដែលនៅជិតខ្ទមអ្នកតា ឬក្រោមដើមឈើធំៗ ហើយអុជធូបនិងចាក់បាយបិណ្ឌទាំងអស់នោះទៅលើដី ដើម្បីឲ្យខ្មោចដែលគ្មានបងប្អូនធ្វើបុណ្យបញ្ជូនឱ្យ។អាចារ្យបានហាមមិនឱ្យលាងចាន និងលាងដៃនៅទីនោះឡើយ ព្រោះហាក់ដូចជាអសីលធម៌ចំពោះខ្មោច ដែលកំពុងទទួល។ បន្ទាប់ពីចាក់បាយបិណ្ឌទៅលើដីអស់គ្រប់គ្នាហើយ អាចារ្យធ្វើពិធីបង្សុកូលច្រូចទឹកលើនំចំណី និងបាយបិណ្ឌឱ្យប្រេតទាំងនោះ ដែលមកចាំទទួលដែរ តែគ្មានញាតិសន្តានឧទ្ទិសឱ្យ។

-បន្ទាប់ពីចប់កិច្ចក្រៅវត្តពុទ្ធបរិស័ទទាំងអស់បានចូលមកកាន់សាលាឆាន់វិញដើម្បីរៀបចំយាគូប្រគេនព្រះសង្ឃឆាន់ពេលព្រឹក។

-ព្រះសង្ឃបានរៀបចំពិធីបង្សុកូល ដើម្បីឲ្យពុទ្ធបរិស័ទរាប់បាត្រ។

-ចាប់ពីម៉ោង៨ព្រឹកទៅ គេសង្កេតឃើញថា មានអ្នកស្រុកអ្នកភូមិបានយកបាយ ម្ហូប នំចំណី ផ្លែឈើគ្រប់មុខជាបន្តបន្ទាប់ ដើម្បីប្រគេនចង្ហាន់ព្រះសង្ឃពេលថ្ងៃត្រង់ និងរាប់បាត្របណ្ដើរៗរហូតដល់ម៉ោង១១។

-ម៉ោង១១ អាចារ្យទូងស្គរម្ដងទៀត ដើម្បីប្រជុំព្រះសង្ឃឆាន់ពេលថ្ងៃត្រង់។

-ពុទ្ធបរិស័ទប្រជុំគ្នាថ្វាយបង្គំព្រះ និងសមាទានសីលចប់ ព្រះសង្ឃធ្វើពិធីជារឆ្លង ដើម្បីជាកិច្ចបញ្ចប់បុណ្យនៃវេននីមួយៗ។ កម្មវិធីដែលដំណើរការបានកន្លងមកហើយនោះ បានអនុវត្តជាបន្តបន្ទាប់ពីមួយទៅមួយថ្ងៃ គឺពីវេនទី១ ឬបិណ្ឌ១ រហូតដល់វេនទី១៤ ឬបិណ្ឌ១៤។ ចំណែកថ្ងៃទី១៥រោចខែភទ្របទគឺជាថ្ងៃបង្ហើយ ដែលគេហៅថា « ភ្ជុំបិណ្ឌ » ព្រោះគឺជាការប្រជុំអ្នកកាន់វេនព្រមទាំងពុទ្ធបរិស័ទ ដើម្បីឆ្លងបញ្ចប់បុណ្យ។ ឯកិច្ចឆ្លងកុសលនេះគេរៀបចំដូចវេននីមួយៗដែរគ្រាន់តែថ្ងៃទី១៥អ្នកកាន់វេនមកចូលរួមគ្រប់គ្នាចំណែកឯពុទ្ធបរិស័ទក៏បានមកចូលរួមច្រើនកុះករ លើសថ្ងៃមុនៗ។ នៅតាមគេហដ្ឋាន នាពេលគោក្របីចូលក្រោល ប្រជារាស្ត្រខ្មែរបានរៀបចំសែនដូនតា ដោយមានរៀបកម្រាលសពីលើខ្នើយ ប្រវែងប្រហែលពីរម៉ែត្រ ដាក់សម្លៀកបំពាក់ឆ្វេងស្ដាំ។ រណ្ដាប់ហូបចុកមាន ម្ហូស្លា បារី បង្អែមចម្អាប ផ្លែឈើ ភេសជ្ជៈ និងទឹកមួយផ្ដិលបង់ផ្កាម្លិះ។ នៅលើចាន ម្ហូបអាហារផ្លែឈើ សុទ្ធតែបានអុជធូបមួយសរសៃ ដើម្បីឱ្យបានជ្រាប ហើយក៏មានអុជទៀនបំភ្លឺព្រោងព្រាតផង។

នៅពេលល្ងាចនោះដែរ គេបានយកស្រទបចេក ឬដើមចេកមករចនាធ្វើជាទូក ឬសំពៅ ទុកសម្រាប់ព្រឹកស្អែក ពេលព្រះអាទិត្យជិតរះច្បាស់ ដើម្បីជូនដូនតាជិះត្រឡប់វិលទៅទីស្នាក់អាស្រ័យវិញ។ នៅលើទូក ឬសំពៅនោះដែរ គេដាក់ចង់តូចៗដែលមានដាក់ស្រូវ អង្ករ ពោត សណ្ដែក ល្ងស... សម្រាប់ទុកជូនដូនតាហូបចុកបន្តទៅទៀត៕

## មោហោ (ភាគគតិ)

លោភោទោសោ កើតពីមោហោ រាល់រូបប្រុសស្រី
គួរកាន់មេត្តា កតញ្ញូខន្តី នេះគឺបាលី
ទៅកាន់បរលោក។

ពាក្យពិតប្រដៅ ឱ្យអស់កូនចៅ ប្រព្រឹត្តរៀនយក
កូនណាមិនរៀន កូនមារយាទថោក នឹងធ្លាក់ជ្រុលជ្រេក
ក្នុងចតុរាបាយ។

ធំស្រេចនៅស្លូត សុខខ្លួនរហូត ដរាបវែងឆ្ងាយ
ខន្តីអំណត់ សង្កត់ក្នុងកាយ ជាតិជនទាំងឡាយ
កម្រកាន់បាន។

ចេះហើយមិនដឹង ចិត្តនៅម្នះរឹង ប្រឹងរកកម្មដ្ឋាន
រកធម៌មិនយល់ ខ្ជិលខ្វល់ឈប់ខាន បន្ទោសបុរាណ
ថាគ្មាននិស្ស័យ។

វិបាបនិងបុណ្យ មានចិត្តជាមុន មាត់ជាបច្ច័យ
នាំចុះនាំឡើង ពីជើងពីដៃ សន្សំសព្វថ្ងៃ
ឈ្មោះហៅសំណាង។

កើតក្នុងលោកិយ រាល់រូបប្រុសស្រី មានចិត្តជាអាង
កុសលអកុសល ប្រទាញសងខាង រូបនៅតែងតាង
តែងតាមទៅមក។

មគ្គផលសីលទាន បើល្ងង់ឱ្យរៀន បើគ្មានឲ្យរក
យល់ល្អសាងស្អាត សង្វាតជ្រៀតជ្រេក ជ្រើសរើសរៀនយក
រក្សារូបកាយ។

## ១-រឿងដើមទៀប និង ដើមសេដា

កាលនោះមានលំនៅឋានមួយប្រកបទៅដោយរុក្ខជាតិចម្រុះស្រស់បំព្រង។នៅប្របរបងខាងមុខមានដើមទៀបមួយដើមដុះនៅក្បែរដើមសេដាមួយដើម។ ក្រោយមកដើមសេដាលូតលាស់បានខ្ពស់បែកមែកសាខាមានផ្លែរណោងរណោងជាច្រើនគួរឱ្យចង់គយគន់។ថ្ងៃមួយដោយឃើញដើមសេដារីកធំធាត់លូតលាស់បានល្អដើមទៀបក៏សួរទៅកាន់ដើមសេដាថាៈហេតុអ្វីក៏បងមានដើមថ្លោសនិងមានផ្លែច្រើនដូច្នេះ?

ដើមសេដាឆ្លើយតបទៅវិញថា ៖

នេះមកពីខ្ញុំទទួលបានជីវជាតិនិងពន្លឺថ្ងៃបានគ្រប់គ្រាន់ល្មម ទើបខ្ញុំដុះលូតលាស់បានលឿន។

ដើមសេដាសួរទៅដើមទៀបវិញថា៖ ចុះហេតុដូចម្ដេច បានជាបងឯងបង់រូបបង់នោមចេះតែស្វិត ស្រពោនទៅៗ បើយើងដុះជិតគ្នាក្នុងទីតែមួយទេ?

ដើមទៀបឆ្លើយតបទៅដើមសេដាវិញថា៖

ឱបងអើយ! ខ្ញុំក្លាយទៅជាស្គមកំព្រឹង គ្មានស្លឹកគ្មានផ្លែបែបនេះ ក៏មកពីខ្ញុំច្រណែននឹងបង ហើយខំប្រឹងលូតឱ្យខ្ពស់ជាងបង តែឥឡូវនេះខ្ញុំស្ទើរតែទប់ខ្លួនមិនជាប់ទៅហើយ។

ដើមសេដាក៏ពោលបន្តឡើងថា៖ ចិត្តប្រកួតប្រជែងមិនអាចខ្វះប៉ុន្តែអ្វីៗមិនគួរបង្ខំហួសមាឌនោះទេ។ពេលក្រោយមកដើមទៀបក៏ក្លាយទៅជាក្រៀមស្វិតក្រញង់រលួយគល់ដួលរលំមកលើដី។

## ២-រឿងទន្សាយ និង ពពែ

មានថ្ងៃមួយ ទន្សាយជាប់អន្ទាក់អ្នកស្រែដាក់នៅតាមផ្លូវចូលចម្ការ ទន្សាយឃើញអ្នកស្រែដើរមកក៏ធ្វើពុតជាស្លាប់។អ្នកស្រែនោះក៏ដោះទន្សាយពីអន្ទាក់យកទៅផ្ទះគាត់បោះទន្សាយនោះទៅកៀនមួយ រួចទៅពុះអុស។ ដល់ទន្សាយមិនឃើញមានមនុស្សសោះ ក៏ងើបឡើងមួយរំពេចហើយបោលយ៉ាងលឿនទៅ។អ្នកស្រែនោះចោលស្នាក់ផ្លូវទន្សាយនឹងអង្កត់អុសត្រូវបាក់ជើងម្ខាង ប៉ុន្តែទន្សាយក៏គង់តែនៅរត់រួច។ដល់រត់ឆ្ងាយបន្តិចទៅ ទន្សាយជួបនឹងពពែមួយចាស់ភ្នែកងងឹតមើលស្ទើរតែមិនឃើញ។ពពែនោះគ្លួញត្អែរពីព្រោះរកស្មៅល្អស៊ីគ្មានទន្សាយក៏និយាយទៅនឹងពពែថា ៖

បងពពែ!ខ្ញុំបាក់ជើងម្ខាងបងឯងភ្នែកងងឹតមើលអ្វីៗមិនឃើញច្បាស់យើងទាំងពីរនាក់ទៅរកស៊ីជាមួយគ្នា ខ្ញុំមើលឃើញបងឯងជើងមាំមួន ឱ្យខ្ញុំជិះលើខ្នង បងឯងចុះ ខ្ញុំនឹងបង្ហាញផ្លូវបងឯង។ ទន្សាយនិងពពែក៏ព្រមព្រៀងគ្នា ហើយនាំគ្នាចូលទៅក្នុងព្រៃប្រទះឃើញមានស្មៅខ្ចីល្អស៊ីឆ្ងាញ់។



ប្រាសាទស្រង់ព្រះ



ប្រាសាទភ្នំជីសូរ